សុទ្ធព្រះបិតាទេ កូនអើយកូន កូននិមិត្តនេះវាសុទ្ធណាស់ៗ បើដូច្នោះកូនហោះទៅនគរមាលីវ័នចុះ ។ វ័យវេតក៏ហោះទៅនគរមាលីវ័ន ហោះទៅដល់ ថាវចក្រវាត់ឃើញ យីឥន្ទជិតអសុរាឬអ្វី ឬក្រុងរាពណាសូរថា ខ្ញុំមិនមែនក្រុងរាពណាសូរទេ បើដូច្នោះឥន្ទជិតអសុរាឬអ្វី ថាទេខ្ញុំមិនបានឥន្ទជិតអសុរាទេ ខ្ញុំនេះពេញ្ញាះហៅថាវ័យវេត អើវ័យវេត អាឯងកូនអ្នកណា ថាកូនក្រុងទសមុខរាពរ រាពណាសូរ អាឯងនេះមុខដប់ដៃម្ភៃ ដូចជាបិតារបស់អាឯង យ៉ាងដូចម្ដេចទៅក្រុងមហេសក្ត្រ តើពេចប្រៀងនឹងព្រះរាម ព្រះលក្សហើយយ៉ាងដូចម្ដេចទៅ ម្ចាស់អើយក្រាស់ ក្ស័យអស់ហើយ ពោកទព្វមហាសមុទ្រអស់ សុទ្ធតែក្បាលយក្ស សុទ្ធតែក្បាលរាជសីហ៍ សុទ្ធតែក្បាលដំរី ក្បាលរមាសទាំងអស់ ក្ស័យទាំងអស់ហើយ ចុះឥន្ទជិតអសុរានោះក៏ក្សិណក្ស័យ ក្រុងទសមុខមារនោះក៏ក្សិណក្ស័យ វិរុលមេឃ វិរុលចំបាំងក្សិណក្ស័យ យីត្រីមុខមហាត្រីកាយក្សិណក្ស័យអស់ហើយ គ្មានអ្នកណានៅទេ សព្វថ្ងៃគឺយកពិភេកអសុរាមកឱ្យសោយរាជ្យ ឱ ទៅអញទៅជួយ បើដូច្នោះទៅវ័យវេត រួចក៏ហោះឆ្លងស្ទឹងអូ ឆ្លងវាលស្មៅ ឆ្លងកាត់សំដៅបីខែដល់ ម្ល៉ោះហើយក្រុងយក្សយង់ ក្រុងអសុរាក៏ហោះមកដល់ក្រុងលង្កាបូរី ក្រុងអសុរាថាវចក្រវាត់ យកសរនាគបាសបាញ់



ពិភេក ឱអានេះអាពិភេក អាថ្លើមខ្មៅ អាឯងអាក្បត់ អាចូលខាងទ័ពមនុស្សា ឥឡូវនេះអាឯងមកសោយរាជ្យក្រុងលង្កា ខាស់ខឹមបូរី ក្រុងអ-សុរីបាញ់សរភ្លែត បាញ់សរនាគបាស កើតជានាគរុំពិភេក ពីជើងទាល់តែដល់ករ សុទ្ធតែនាគរុំទាំងអស់ ក៏ផ្អើលលាន់តែម្ដង ថាវចក្រវាត់ក៏វិលទៅវិញ ផ្អើលរវល់សេនារេហ៍ពលសកលយោធា មិនមានអ្នកណានៅបៀតឡើយ នៅតែនិលផាត់ ឱនិលផាត់ហោះទៅរកសហ-នុមាន ហោះទៅប្រាប់កេសរជម្ពូពាន ហោះទូលព្រះនារាយណ៍រាមា និលផាត់ហោះមកដល់នគរស្រីអយុធ្យា ដូច្នោះហើយ ក៏ឡើងទៅម៉ប ក្រាបថ្វាបង្គំ ព្រះនារាយណ៍រាមា ថាមានយក្សមួយធំណាស់មួយចំហៀងមេឃា ឈ្មោះថាវចក្រវាត់ នៅនគរមាលីវ័ន មកបាញ់មាពិភេក កើតជានាគរុំពីជើង ទាល់តែដល់កសុទ្ធតែនាគរុំ មិនដឹងជាយ៉ាងណាទេ ព្រះនារាយណ៍រាមាក៏បរពល បរពលស្វាប៉ែតសិបអក្ខោជិនុំអស់ពួកកងសេនាទាំងពីរដណ្ដប់អង្គប្រាណដល់មកហើយ ឃើញពិភេកអសុរាត្រូវសរនាគបាសរុំអំពីជើងទៅដល់ក ព្រះនារាយណ៍រាមាសរសេរអក្ខរា បិតនឹងចុងសរថ្លែងសរបាញ់ទៅឋានសួគ៌ាល័យ ឱ្យបានដល់ទៅព្រះបាទឡីសតីដូចសេចក្ដីប្រាថ្នា បាញ់សរអារិទ្ធីចាន់ផ្កាញផ្លា បាញ់ភ្លែតទៅព្រះបាទឡីស-

ពិចាប់ជាប់ ចាប់សរជាប់ថាព្រះរាមព្រះលក្សណ៍មនុស្សាមានក្រហ៊ើយៗ ថាវិចក្រវាត់បាញ់សរនាគបាស រុំអំពីជើងទើសតែដល់ក ព្រះបាទឡើសតី ស្តេចក្រុឌ ថានែព្ភាយើងប៉ុន្ទានរក្ខោចុះទៅឱ្យឆាប់ជាប្រញាប់ ព្បិតពីរពិភេក ត្រូវសរនាគបាសហើយ សុទ្ធតែគ្រុឌ គ្រុឌហោះមកពេញកណ្តាប់ អេហោ ថាតែគ្រុឌបោះបកនាគវាលោត គ្រុឌខ្លះចាប់បាននាគយកមកខាំ គ្រុឌខ្លះចាប់ទាញនាគ ម៉្លោះហើយនាគខ្លះក៏សឹងរត់ចូលមហាសាគរ នាគខ្លះជ្រែកព្រៃហេមពាន្ត នាគខ្លះជ្រែកដោយនៅរូងភ្នំ សឹងដ៏ខ្លាចគ្រុឌ ពិភេកអសុរាក្រោកឡើងដឹងខ្លួនប្រាណដូច្នោះហើយ ថាអើរឿងនេះតើហេតុមកអំពីអ្វី ថាហេតុមកអំពីវិយវេត ទៅយកថាវិចក្រវាត់ ពេចាប់វិយវេត ចាប់វិយវេតបានយកទៅសម្លាប់ សម្លាប់ក្សិណក្ស័យប្រល័យជីវិត ទៅដូច្នោះហើយ ទើបលើកទ័ពទៅនគរមាលីវ័ន ទៅនគរថាវ-ចក្រវាត់ ដែលលើកទៅច្បាំងនោះ ទ័ពស្វាច្រើនសល់ ទៅដល់កក្រើកនគរថាវិចក្រវាត់ ឯនគរថាវិចក្រវាត់នោះ មានខ្សាច់ហូរនៅខាងក្រោម នរណាចូលទៅរួចទេនគរនោះ ម៉្លោះហើយក៏លើកទ័ពទៅវាយ លើកទៅវាយនគរថាវិចក្រវាត់ ថាវិចក្រវាត់តម្លើងអង្គប់ភ្នំ ពលស្វាដើរចូលទៅក្នុងអង្គប់ភ្នំ វាថ្លោះអង្គប់ភ្នំមក ធ្លាក់ទៅលើពលស្វា ងាប់



ពលស្វាប៉ែតសិបអក្ខោ ព្រះនារាយណ៍រាមាក៏ឆ្ងល់ណាស់ ថាអើពលពានរស្វាស ហេតុអ្វីក៏មកក្ស័យយ៉ាងនេះ យក្សវាតម្លើងអង្គប់ភ្នំ អង្គប់នោះធំៗ អង្គត់ហនុមានបាសុគ្រីព ថាព្រះអវតានកុំព្រួយព្រះទ័យ តាំងលើកភ្នំ លើកទៅឃើញពានរក្ស័យច្រើនក្រៃ ឱ្យអង្គត់ហោះទៅឋានព្រហ្ម ឱ្យទៅយកទឹកអម្រិតព្រះឥន្ទ្រាមកស្រោចឱ្យពានរ ពានរក៏រស់ទាំងអស់ ស្រោចត្រូវមួយរត់មួយត្រូវពីររត់ពីរ ក៏រស់អស់ ពីដើមស្លាប់គំនរគរគរដូចភ្នំនេះរស់អស់គ្មានសល់ ថាតែរស់អស់គ្មានសល់ហើយ កាលណោះថ្ងៃរសៀលជ្រៀលជ្រេទេរព្រះសុរិយា ដើរនោះគឺសុគ្រីព អង្គត់បាហនុមានចូលទៅ ក្នុងនគរថាវិចក្រវាត់ ហើយនិយាយពីបាវពលសកលយោធារបស់វា កាលបើឃើញស្វាធំៗ ប៉ុនភ្នំស្ទឹមស្ទែ សង្ស័យណាស់ ស្វាមកពីណាក៏ធំៗ ខ្លាំងម្ល៉េះ រំលាយប់នោះវាយាមនគរវា ចុះនរណាអ្នកយាមនគរ ថាយក្សជីវ័ក្ខ អាយក្សជីវ័ក្ខនោះ វាលៀនអណ្តាតគ្របនគរអង្គរបូរីទាំងអស់ យក្សជីវ័ក្ខលៀនអណ្តាត លៀនបានគ្របនគរវាទាំងអស់ ។ ថាតែលៀនអណ្តាតគ្របអង្គរទាំងអស់យ៉ាងនេះទៅ និយាយពីសោបនក្លាមកពីលេងព្រៃ យីអ្វីក្រហាមម្ល៉េះ ភ្លើងឆេះនគរឬអ្វី ភ្លើងឆេះនគរឬអ្វី ភ្លើងឆេះនគរឬសឹកឈាមសង្គ្រាមជ័យ ទ័ពភ័យសារមកពីណាបាន

ជាក្របាបពេញនគរយ៉ាងនេះ ស្រាប់តែវាទាញកងចក្រមកចោល ចោលមកត្រូវអណ្ដាតគ្នាវា ត្រូវអណ្ដាតដែលល្បៀនគ្របនគរ នោះអាយក្សជីវ្ហាស្លាប់ពេលនោះ ដែលស្លាប់ពេលនោះទៅ ថាវិចក្រវ៉ាត់ក៏បានដឹង ដឹងថា យក្សជីវ្ហាស្លាប់ដូច្នោះហើយ ថាវិចក្រវ៉ាត់ដែលនៅក្នុងនគរហាលីវ៉ិននោះ ពេលនោះមារអង្គត់ ហនុមាន ពាសុគ្រីពឧត្តម តាំងសណ្ដំយប់ឡើងសណ្ដំ សណ្ដំយក្សទាំងអស់ ដេកលក់ស្ងប់ស្ងាត់បាត់វិញ្ញាណដូច្នោះហើយ ដល់ពេលពេលឡើងក៏ចូលទៅ ចូលទៅឯនាងស្រីស្នំក្រមការបណ្ដារយក្សដែលអ្នកដេកនៅខាងក្រៅប្រាសាទ · អ្នកយាមល្បាតក៏សឹងដំត្រូវសណ្ដំ ពានរស្វាសទាំងអស់ ម៉្លោះហើយហនុមានថា ធ្វើដូចម្ដេចបាអង្គត់ ឥឡូវយក្សវាដេកលក់អស់ហើយ គិតដូចម្ដេចយើងគិតកោរក្បាលវាទៅ កោរក្បាលវាទៅខ្លែងជើងក្អែកខ្លះទៅ តាំងកោរក្បាល កោរក្បាលមិនថាពលថានាយ មិនថាបាវមិនថាព្រាវអ្វីទេ សូម្បីតែស្ដេចយក្សឯណាក៏កោរក្បាលវាទាំងអស់ ដល់ព្រឹកព្រាងស្វាងព្រះបរមីតា មានស្រីស្នំក្រមការ ឡើងទៅគង់គាល់មហាយក្សថាវិចក្រវ៉ាត់ ថាវិចក្រវ៉ាត់ថាឃីនាង ពីដើមមិញរូបនាងល្អ ឥឡូវនេះនរណាមកកោរក្បាលនាងនោះ ស្ទាបទៅឃើញគេកោរក្បាល ខ្វេងជើងក្អែក ឃីយល់ជាចម្លែក



ប្លែកណោស់មើលទៅថាឃីសិរិសាម្ចាស់ តើគេកោរ ស្ទាបទៅក្បាលឃើញគេកោរទាំងអស់ អ្នកណាក៏កោរ ១ កោរតែទាំងអស់គ្នា ក៏ថា ឱគ្មានពីណោះទេ ច្បាស់ជាអាស្វាធំ កាលពីថ្ងៃល្ងាចនោះឯងវាមកកោរ ។ ក្រុងថាវិចក្រវ៉ាត់ កាលណោះបើដឹងថា គេកោរក្បាលអាត្មា នឹងស្រីស្នំក្រមការដូច្នោះហើយ ក៏ក្រេវក្រោធពិរោធសោះសា យក្សវាយស្គរទ័ពភ្ញុំកងសេនា ចាប់ពួកអាស្វាសយក្សឱ្យបាន គឺអង្គត់បាហនុមាន បាសុគ្រីពក្រុងថាវិចក្រវ៉ាត់ក៏កេណ្ឌកងពួកយក្សយង់ក្រុងអសុរា ពួកពលបានដឹងពានព្លកាលណោ ក៏ហោះមកអំពីព្រៃហេមពាន្តច្រើនត្រៀបត្រា ក្រុងថាវ-ចក្រវ៉ាត់ក៏មានព្រះឱង្ការទៅកាន់ពួកកងសេនាយក្សទាំងអស់ យើងទៅឡោមចោមចាប់ពានរស្វា ម៉្លោះហើយ លើកទ័ពគគ្រឹកកក្រើកព្រៃសព្វសត្វដទៃក៏តក្កមា រមាំងរមាសខ្លោងខ្លាក៏រត់ចោលកូនពីកន្លែង ក្រុងថាវចក្រវ៉ាត់ក៏លើកទ័ពមកឮសូរស័ព្ទ ដូចព្យុះឮដូចផ្គររន្ទះគគ្រាំងអា ពេលនោះពិភេកសា ក៏ថ្វាយបង្គំព្រះរាមាទូលថាក្រុងអសុរាលើកទ័ពមកហើយព្រះនារាយណ៍រាមាបានស្ដាប់ពិភេកសាដូច្នោះហើយ ពុំយូរឡើយព្រះអង្គក៏ភ្ញុំពួកសេនាទាំងពីរដល្ហេប់អង្គប្រាណ , សុគ្រីពហនុមាន កេសរជម្ពូ-ពាន និលឯកនិលខាន់ និលផាត់ រួចបានហើយទើបលើកទ័ពទៅទល់មុខ

ធ្លា ពលយក្សនឹងពលស្វាក៏ចូលចំបាប់ ចាក់កាប់សម្លាប់គ្នាច្រើនសល់ ថាវ៍ចក្រវ៉ាត់ក៏បានថ្លែងសរ មកចំព្រះនារាយណ៍រាមា សរយក្សាហួស ជ្រួសទៅព្រៃហេមពាន្ត ក្រុងយក្សាក្រេវក្រោធខ្លាំងក្រៃ យក្សបាញ់សរ ជ័យរេះកើតភ្លើង អង្គព្រះនារាយណ៍រាមាកាលណាបើឃើញដូច្នោះហើយ ព្រះអង្គក៏ទាញធ្នូសរថ្លា អាវិទ្ធិចាន់ថ្លាញថ្លា បាញ់កើតភ្លៀងរំលត់ភ្លើង អសុរមារ ភ្លើងកងអគ្គីរលត់ រម្លាប់អស់គ្មានសល់ ម្ល៉ោះហើយថាវ៍ចក្រ-វ៉ាត់ ក៏ថ្លែងសរនាគបាសមកថែមទៀត កើតជានាគពេញកណ្តាប់មេឃា អង្គព្រះនារាយណ៍រាមាឃើញហើយ ក៏ចាប់សរបាញ់ទៅទៀត ក៏កើតជា គ្រុឌចាប់នាគស៊ី សត្វនាគក៏ភ័យភិតរត់ជ្រកក្នុងរូងភ្នំ នាគខ្លះក៏ជ្រែកជ្រៀត ឆ្មៀតទៅនៅច្រករូងភ្នំ ខ្លះទៅនៅក្នុងមហាសមុទ្រធំ ក្រុងថាវ៍ចក្រវ៉ាត់ ក្រេវក្រោធខ្លាំងណាស់ដូចជាភ្លើង ម្ល៉ោះហើយបាញ់សរឱ្យកើតជាអាវុធ គ្រៀបគ្រា អង្គព្រះនារាយណ៍រាមាព្រះអង្គក៏ចោលចក្រ ចក្រមានឫទ្ធិ ខ្លាំងអស្ចារ្យ ដេញអាវុធយក្សាធ្លាក់ទៅក្នុងមហាសមុទ្រ ក្រុងថាវ៍ចក្រវ៉ាត់ ខ្ទាល់ណាស់ទាញដំបងពេជ្រគ្រីសុទ្ធតែភ្លើង ប្រុងមកវាយវ៉ាត់សំពង ព្រះ នារាយណ៍រាមាយកធ្នូសរ អាវិទ្ធិចាន់រងវាយវ៉ាត់សំពងសងក្រុងអសុរាវិញ ថាវ៍ចក្រវ៉ាត់ តនឹងអង្គព្រះនារាយណ៍ក៏ចាញ់ដៃ ព្រះនារាយណ៍ក្សត្រ



ថ្លៃវាយចំអង្គអសុរា ហោះទៅកណ្តាលអាកាសាស្រទាប់មេឃា ពេលនោះ ថ្លែងពេលពេលកលយោធា យក្សស្លាប់មរណាពេញមហាសមុទ្រធំពួកពានរ ស្វាសអោនជ័យរំណាចគ្មានស្លាប់មួយ ហនុមានបាអង្គត់បាសុគ្រីពកេសរ ជម្ពូពាន កាត់កកាត់ខ្លួនយក្សាបោះទៅកណ្តាលមហាសាគរ ឃុនល់ ឃុនមិល និលឯក និលខាន់ និលផាត់ កាន់ដំបងពេជ្រវាយបំបែកពលយក្សា យក្សស្លាប់មរណាអស់គ្មានសល់ កាលណោះ អង្គព្រះនារាយណ៍រាមា ស្តេចក៏ឆ្ងល់សួរពិភេកអសុរាថាប្អូនអើយ យក្សច្បាំងមុិញមុិញវាទៅណា ពិភេកអសុរាគន់គួរឃើញហើយក៏ទូលថា យក្សាទៅបំបាំងខ្លួននឹងពពក ក្រាលយក្សានឹងលួចបាញ់សរមកឥឡូវ កុំព្រះអង្គមកបង្អង់យូរឡើយ ឱ្យ ឆាប់ថ្លែងសរអាវិទ្ធិចាន់ឆាប់ៗទៅព្រះនារាយណ៍រាមាបានស្តាប់ពាក្យពិ-ភេកថាដូច្នោះហើយ ពុំយូរឡើយព្រះអង្គបាញ់សរអាវិទ្ធិចាន់ត្រូវត្រង់ដើម ទ្រូងយក្សយង់អសុរា យក្សាក៏ធ្លាក់មកលើផែនដី ឮដូចភ្នំធំរណ្តំគ្នា ក៏ ផ្អៀងផែនដី ព្រះអង្គហូតព្រះខាន់ថ្លា អារផ្តាច់សុរ៉ាំងក្រុងអសុរី ក្រុងយក្ស អប្រិយក្ស័យមរណា ស្លាប់បាវពលទាំងអស់ក៏សោះសូន្យ ឥតមានយក្ស យង់ក្រុងអសុរា ពលទ័ពឯណាមកតនឹងព្រះអង្គទៀតឡើយ ព្រះអង្គក៏ លើកកងទ័ពវិលមកវិញ ពួកទ័ពសារក៏បានវិលចូលមកបុរី ។

៦៩-និយាយពីកូនឥន្ទជិតអសុរានាមឈ្មោះថា អាផៃណាសូរីវង្ស កើតមកថ្ងៃណាស្មានថាពិភេកអសុរាជាបិតា ចេញទៅលេងកាលណា មានស្រីស្នំប្រាំពាន់ឆ្វេងប្រាំពាន់ស្តាំ អាផៃណាសូរីវង្សស្រែកថា សប្បាយណាស់ ធម្មតាជាស្តេចចក្រ គ្មាននរណាសប្បាយប្រហែលយើង កាលនោះមានតាមាលីសូន នឹងនាងភីល្បៀងទាំងបូន ថ្វាយព្រះបង្គំសុំក្រាបទូល សប្បាយអ្វីប៉ុណ្ណេះ មិនថាសប្បាយទេ កាលព្រះបិតាម្ចាស់នៅសប្បាយជាងនេះ ព្រះបិតាម្ចាស់មានរិទ្ធណាស់ បើចេញទៅត្រង់ណាមានទេវតាហោះហែរ បើចេញទៅត្រង់ណាមានទេពអប្សរហោះហែរ អាផៃណាសូរីវង្សក៏បានស្តាប់តាមាលីសូននឹងសេនាទាំងបួន ថាដូច្នោះហើយមានព្រះឱង្ការថាតាអើយ ខ្ញុំមានបិតាឯណាទៀត ពិភេកអសុរានេះហើយបិតារបស់ខ្ញុំ មិនមែនទេម្ចាស់ នេះគឺពិភេកអសុរាទេ បិតាម្ចាស់គឺឥន្ទជិតអសុរា មកអំពីពិភេកអសុរានេះឯងសម្លាប់ព្រះបិតារបស់ម្ចាស់ សម្លាប់ជីតាម្ចាស់ ចូលទ័ពជាមួយទ័ពមនុស្សា សម្លាប់អស់ទាំងវង្សាវតារប្រាំពីរសណ្តានរបស់ម្ចាស់ យក្សស្លាប់ពំនរគោករស់នព្វមហាសមុទ្រ អាផៃណាសូរីវង្ស កាលណាបើបានស្តាប់ភីល្បៀងទាំងបួននឹងតាមាលីសូនទូលដូច្នោះហើយ ក៏ទ្រង់ព្រះកន្សែងសោយសោកា ឱ ព្រះបិតា



កាលណាខ្ញុំកើតមក ខ្ញុំមិនបានឃើញព្រះភក្ត្រ សោយសោកវិយោគខ្លាំង ក៏ឡើងគាល់ព្រះវររាជមាតាទូលថា ព្រះបិតារបស់ខ្ញុំ ពិភេកអសុរាឬមិនមែនទេ មាតាប្រាប់ថាកូនអើយមិនមែននេះទេ នេះជាពិភេកអសុរាជាឪពុកធំបាឯង អាផៃណាសូរីវង្ស សួរថាបិតារបស់ខ្ញុំឈ្មោះអ្វី ម្តាយប្រាប់ថា បិតាបាឯងឈ្មោះឥន្ទជិតអសុរា មកអំពីពិភេកអសុរានេះឯង នាំព្រះរាមព្រះលក្សណ៍មនុស្សាមកសម្លាប់បិតារបស់បា សម្លាប់ទាំងព្រះជីតាឈ្មោះក្រុងរាពណាសូរ សម្លាប់ទាំងពូជពង្សអំបូរប្រាំពីរសន្តានអាផៃណាសូរីវង្សក៏បានស្តាប់ព្រះមាតាថាដូច្នោះហើយ អ្នកក៏ឆេះឆួលក្តៅក្នុងឱរា សួរព្រះមាតាបន្ថែមទៀតថា យើងមានពូជពង្សវង្សានៅឯណាខ្លះ ម្តាយប្រាប់ថាកូនអើយ ពូជពង្សយក្សានៅតែស្តេចយក្សមួយទេ ស្តេចយក្សនោះធំណាស់ ធំលើសយក្សក្នុងផែនដី ពូកែលើបិតារបស់អ្នក ពូកែលើជីតារបស់អ្នក ក្នុងពិភពលោកនេះគ្មាននរណាពូកែលើយក្សនោះទេ ស្តេចយក្សនោះពូកែមូរផែនដីបាន ធម្មតាជាយក្សក្នុងពិភពលោក នឹងរកយក្សឯណាធំប៉ុនគ្មាន យក្សនោះធំបាំងមួយចំហៀងមេឃ ស្ទើរតែនឹងលេបផែនដីបាន នាមឈ្មោះហៅថា មហាស្រកាចិន្តាភាពណ៍ កូនអើយនៅនគរនោះហៅមហាឆ្វាយ បើគ្រាន់តែហោះយ៉ាង

លឿន បីខែទើបបានដល់ អាផៃណាសូរីវង្សបានស្តាប់មាតាថាដូច្នោះ ហើយព្រួតអរក្នុងចិត្តមិនមានស្បើយ ខ្ញុំសូមក្រាបបង្គំលាព្រះមាតា ខ្ញុំសុំហោះទៅនគរមហាស្រកាចិន្តាភាពណ៍ ព្រោះថាទេ កូនទៅពីនគរគេមិនទទួលស្គាល់យើងទេ អាផៃណាសូរីវង្សទូលមាតា ធ្វើភេទយ៉ាងណាទើបទៅបាន ព្រោះថាកូនវើយ បើចង់ទៅឱ្យកូនហោសហោរាការ៉ាប្រាណឱ្យកើតដូចរូបបិតាទើបទៅបាន អាផៃណាសូរីវង្សទូលមាតា ថាបិតារូបយ៉ាងដូចម្តេច កាលណោះបានគូររូបនៅនឹងថតកញ្ចក់ ម្តាយយកពំនូរមកឱ្យមើល អាផៃណាសូរីវង្ស មើលឃើញរូបព្រះបិតាហើយសូធ្យមន្តព្រះគាថា ប្រែកាឡាឱ្យបានសុទ្ធដូចរូបព្រះបិតា រួកថ្វាយបង្គំលាហើយ ក៏ហោះទៅនគរកែវចក្រវាឡនាយ ក៏ចូលទៅថ្វាយបង្គំមហាស្រ-កាចិន្តាភាពណ៍ មហាស្រកាចិន្តាភាពណ៍ក្រឡេកឃើញសួរថា អាណាមកពីណាឥន្ទជិតអសុរាឬអ្វី ? អាផៃណាសូរីវង្សក៏ក្រាបទូលថា ខ្លួនខ្ញុំនេះមិនមែនឥន្ទជិតអសុរាទេ មហាស្រកាចិន្តាភាពណ៍ថា បើអាឯងមិនមែនឥន្ទជិតអសុរា ម្តេចក៏សុទ្ធម្ល៉េះ អាផៃណាសូរីវង្សថា ខ្ញុំនេះកូនឥន្ទជិត ចុះអាឯងហេតុដូចម្តេច ទើបអាមកមានការអ្វី អាផៃណាសូរីវង្សទូលថាព្រះញាតិទាំងប្រាំពីរសន្តានក៏ក្ស័យអស់ ឥន្ទជិតអសុរាក៏ក្សិណក្ស័យព្រះ



ជីតាក៏ក្សិណក្ស័យ ពូជពង្សយក្សាទាំងប៉ុន្មានក្ស័យទាំងអស់ មហាស្រកាចិន្តាភាពណ៍សួរថា ហេតុអ្វីក៏ក្ស័យ អាផៃណាសូរីវង្សទូលថា ពិភេកអសុរារត់ចូលទ័ពជ័យព្រះរាមព្រះលក្សណ៍មនុស្សាមកសម្លាប់បិតារបស់ខ្ញុំ សម្លាប់ជីតារបស់ខ្ញុំ សម្លាប់ពូជពង្សវង្សាប្រាំពីរសន្តាន មហាស្រកាចិន្តាភាពណ៍បានស្តាប់ហើយគ្រាន់តែយកដៃគក់ដើមទ្រូង ផ្អៀងផែនដី ភ្នំដូចគេរលំរលើងលើព្រៃ ក្រុងរវសុរីត្រាស់ថា ឯងទៅមុនចុះ អញលើកទ័ពទៅក្រោយ ទៅសម្លាប់អាមនុស្សាឱ្យបាន ថាហើយកេណ្ឌកងទ័ពពេញកម្រោប់ចក្រវាឡ ព្រៃហេមពាន្ត ទ័ពយក្សាទាំងអស់គ្មានសល់ចន្លោះត្រង់ណាឡើយ តាមកោងសមុទ្រសុទ្ធតែយក្ស យក្សខ្លះកំពស់មួយរយយោជន៍ យក្សខ្លះជើងវាទល់ដី ក្បាលទល់ស្រទាប់មេឃា ពួកពលយោធាអស់អស្ចារ្យក្រៃ ពួកពលទាំងអស់សុទ្ធតែឫទ្ធិ បាំងសែងព្រះអាទិត្យអាប់រស្មីខ្លះហើរ ខ្លះហោះ ខ្លះដើរដី មហាស្រកាចិន្តាភាពណ៍ ក៏នៅលើបុស្បុកនីកទៅត្រង់ណា អណ្តែតទៅត្រង់ណោះ ម្ល៉ោះហើយសួរស័ព្ទសន្ធឹកផ្អៀងផែនដី សូរស័ព្ទកក្រើករបើកព្រៃ បានលើកបៀតមកដល់ក្រុងលង្កាបូរី ញាប់ញ័រអស់ទាំងផ្ទៃ ភ័យរាល់គ្នា . ពិភេកអសុរាប្រើកងសេនាទៅទូលព្រះនារាយណ៍រាមា អាមាត្រទៅដល់ម៉បម៉ាយថ្វាយបង្គំ ពិភេក

អសុរាប្រើអញខ្ញុំមកទូល ព្រះអង្គយាងទៅឱ្យឆាប់ ដ្បិតអីមានពួកសង្គ្រាម ជ័យទ័ពភ័យសារ ឱ្យព្រះអង្គយាងទៅឱ្យឆាប់ ព្រះនារាយណ៍រាមាស្តាប់ហើយ ភ្ញុំកងពលពានរចល់ចេញប្រញាប់ ភ្ញុំពួកសេនាដប់ពីរអង្គប្រាណ ទើបព្រះអង្គចរផ្ទានបានមកដល់ក្រុងលង្ការាជបូរី ពិភេកសារចូលថ្វាយបង្គំ ទូលអង្គព្រះនារាយណ៍រាមាក្សត្រាធិបតី ទ័ពនេះទ័ពធំលើសទ័ពណាៗ គឺមហាស្រកាចិន្តាភាពណ៍ បានតែព្រះអង្គស្តេចលីលាបរពលទាំងអស់គ្នាកុំឱ្យសល់ ម្លោះហើយព្រះនារាយណ៍រាមា ភ្ញុំកងយោធាទៅទាំងអស់ បាសុគ្រីព កេសរជម្ពូរពាន និលផាត់ ពិភេក ហនុមាន បារអង្គត់ ស្តេចលើកចតុរង្គយោធា បានទៅជួបមុខទ័ពគ្នា ក្នុងពេលនោះនៃ ស្វាទឹងយក្សកាប់ចាក់ប្រឡូកប្រឡាក់ជួបមុខគ្នា ព្រះនារាយណ៍រាមាថ្លែងសរជ័យ សរអារិទ្ធីចាន់ក៏ផ្លាញផ្លាស្លាំពលយក្សរាដប់ពីរសមុទ្រ កាលណោះមហាស្រកាចិន្តាភាពណ៍យល់ជាពលក្សិណក្ស័យប្រល័យជន្ម ស្លាប់អស់មិនមានសល់ យក្សស្លាប់គោកសមុទ្រអស់ប្រាំពីរខ័ណ្ឌឈាមយក្សឈាមសត្វប្រឡាក់គ្នា ស្អុយក្នុងគង្គាមហាសមុទ្រ កាលណោះមហាស្រកា-ចិន្តាភាពណ៍ហោះមកជិតជុំចងហ៊ុំចាប់ឱ្យបាន អង្គព្រះមហាក្សត្រក្សាន្តក៏បាញ់សល់ មហាស្រកាចិន្តាភាពណ៍ ស្រកាវាប៉ុនភ្នំ សុទ្ធតែពេជ្រដុះជុំខ្លួន



អសុរា បាញ់សរត្រូវហើយមិនមុតខ្លាំងសោះសា បាញ់ខ្លាំងព្រាយកើតភ្លើងភ្លឺសូត្រា សុគ្រីព អង្គត់ ហនុមាន កេសរជម្ពូរពាន នាំគ្នាឱបភ្នំយំសោះសា មើលទៅខ្លួនឯងមិនបានប៉ុនម្រាមជើងវា ព្រះរាមបាញ់សរប្រាំពីរយប់ប្រាំពីរថ្ងៃ ត្រូវហើយមិនមុតបន្តិចឡើយ បាញ់ឡើងជិតឡើងៗ ព្រះនារាយណ៍រាមា អស្ចារ្យក្រៃ ព្រះឥន្ទ្រាយកគ្រែមាស ពីសូត្រាមកឱ្យស្តេចពង់ បាញ់ខ្លាំងណាស់ប្រាំពីរយប់ប្រាំពីរថ្ងៃ ដាច់ចន្លោះសរជ័យវិលផែនដី ពេក្រុមោះបោះពេកជាជិតព្រៃ បបរក្សព្រថ្លៃទ្រង់ព្រះកន្សែង ឱស្រីមេក្សណ៍អនុជាពុំងាប្អូន ជីវិតយើងសោះសូន្យថ្ងៃនេះហើយ ថាហើយស្តេចបីអង្គា ស្រីលក្សណ៍អនុជា ពិភេកអសុរា ព្រះនារាយណ៍រាមាក្បែកក្តាយំ ព្រះនារាយណ៍រាមាទ្រង់ព្រះកន្សែងថា ពិភេកអសុរាមាសបងអើយ យើងបីអង្គាក្សិណក្ស័យពេលនេះហើយ ។ សុគ្រីពអង្គត់កេសរជម្ពូរពាន បាហនុមាន និលផាត់ និលឯក នាំគ្នាឱបភ្នំយំខ្លាំងក្រៃ បើម្ចាស់យើងក្សិណក្ស័យយើងក្ស័យទាំងអស់គ្នា និយាយពីពលស្វាប៉ែតសិបអក្ខោខ្លះរត់ខ្លះយំ រត់ចូលព្រៃ ពេលនោះពិភេកអសុរា គន់គូរហោរាដោយទិព្វ-ចក្ខុជា ម្ចាស់អវតានកុំព្រួយព្រះទ័យ កុំសោយសោកាយំ យើងទាំងអស់គ្នា នៅតែមួយនាទីទៀតមានអង្គទេវបុត្រ វិស្សុកម្មទេវបុត្រចុះមកឥឡូវ

មកតបន្ទោះសរជ័យបានដូចចិត្ត ពេលនោះវិស្សុកម្មអង្គទេវបុត្រ មកតបន្ទោះសរជ័យកើតជាថ្មី សុំព្រះនរបតីបាញ់សរទៀត កាលណោះពិភេកអសុរាទូលអង្គក្សត្រាព្រះនរបតី ក្រុងអសុរីក្ស័យថ្ងៃនេះហើយ ចាំឱ្យមកជិតសិនកុំទាន់ថ្លែង កាលណោះមហាស្រកាយក្សយង់អសុរា មកឱ្យជិតនឹងចាប់អង្គក្សត្រា ពិភេកទូលថា ឱ្យព្រះអង្គថ្លែងសរទៅ អធិដ្ឋានថា ឱ្យអរិទ្ធិចាន់សរថ្លា កើតជាអង្គព្រះព្រហ្ម មហាស្រកាចិន្តាភាពណើកាលណោ បើឃើញអង្គព្រះព្រហ្មលើកដៃថ្វាយបង្គំថា លោកត្រូចុះមកជួយ ពិភេកចង្អុលត្រង់រន្ធក្លៀក មានតែប្រហោងត្រង់ណោះឯងចុះសរអរិទ្ធិចាន់ព្រះនារាយណ៍រាមាស្តាប់ពាក្យពិភេកអសុរាទូលថាហើយ ស្តេចចាប់សរជ័យបាញ់ចំរន្ធក្លៀកអសុរី សរត្រូវខ្លាំងក្រៃ ក្រុងអសុរីក៏ធ្លាក់មកកណ្តាលភឹនផែនពសុធា ផ្ទៀងទាំងផែនដី ក្រុងអសុរីក្សិណក្ស័យមរណា ។ ព្រះរាមព្រះលក្សណ៍មនុស្សាក៏បរពលស្វា មកដល់ក្រុងលង្ការាជបូរី ផ្តាំពិភេកអសុរា ថាព្រះអនុជអរូន សោយរាជ្យនឹងនេះចុះ សហនុមានបាននាងបុញ្ញកាយ ទៅសោយរាជនៅសហកោះក្រៃព្រះជ័យលង្កា សហនុ-មានក៏បាននាងបុញ្ញកាយ បាននាងមច្ឆានព្វ ។



៧០-ថ្លែងពីព្រះនារាយណ៍រាមា លើកពលសកលយោធាចូលក្នុងនគរស្រីអយុធ្យា ព្រះបាទទសរថរាជា ឱ្យភិរុតសមុទ្រទ្រុត ដកឃ្លាទៅសោយរាជ្យនគរកៃយកេតបូរី ព្រះអង្គក៏សោយរាជ្យនគរស្រីអយុធ្យាបានសុខសាន្ត ព្រះអង្គបញ្ជូនសរទៅឋានសួគ៌ាទាំងអស់ ឥតមានទ័ពភ័យសារអកពីណោទៀតឡើយ ព្រះអង្គគង់នៅជាសុខសាន្ត ។

៧១-មានកាលមួយថ្ងៃព្រះនារាយណ៍រាមា ក្សត្រថ្លៃព្រះអង្គអផ្សុកក្នុងព្រះរាជហឫទ័យ ហៅសហនុមានស្រីលក្សណ៍អនុជា ហៃប្អូនពុំងាជូនបងទៅលេងព្រៃ សហនុមានស្រីលក្សណ៍អនុជា ឮព្រះនារាយណ៍រាមាព្រះអង្គមានព្រះឱង្ការដូច្នេះហើយពុំយូរឡើយ ក្រាបថ្វាយបង្គំព្រះនា-រាយណ៍រាមាត្រាស់ថាអរអូនអើយ យើងគិតទៅលេងព្រៃ ម្ល៉ោះហើយស្តេចទាំងបីអង្គាស្តេចចរចូលទៅលេងព្រៃ ព្រះនេត្ររំពៃមើលសត្វបក្សាសត្វដើរសព្វហើរច្រើនក្រាសក្រៃ ព្រះមហាក្សត្រថ្លៃបានទៅដល់ដើមពោធិជ្រៃមួយណាដើមនោះធំមានមែកសាខាមានស្រះមួយណាទឹកថ្លាយល់ដីព្រះអង្គទ្រង់ផ្ទំក្រោមដើមព្រះជ្រៃ ព្រះលក្សណ៍ក៏ផ្ទំបៀតបង សហនុមានប្រែប្រាណកាឡា កើតជាកូនស្វាច្របាច់ជើងក្សត្រក្សាន្ត ទីឋានត្រង់ណោះសុទ្ធតែទីឋានយក្សាស្តេចយក្សឈ្មោះកុម្ភណ្ឌបុរណារាត ប្រើកុម្ភណ្ឌទាំងបួនឱ្យរក្សា

ស្រះ ស្រះនោះល្អណាស់មានឈូករំចង់ ឈូកសឈូកសែតឧត្បលខៀវ ស មានផ្កាមហាហង្សរំចង់មាលតី មានផ្កានូនស្រីប្របឆ្នេរស្រះស្រង់ កាលណោះពួកយក្សកុម្ភណ្ឌទាំងបួន យាមល្បាតជិតជុំ ដល់ដើមពោធិ៍ជ្រៃសាខា ឃើញព្រះនារាយណ៍រាមា និង ស្រីលក្សណ៍អនុជា ថាអង្គព្រះឥន្ទ្រានឹងទេវបុត្រ បោតុអ្វីមានកូនស្វាប្របាច់ជើង មកវើយធ្លាយើងមកចោបចាប់ឱ្យបាន យកទៅថ្វាយអង្គម្ចាស់លើត្បូងសិរសា ចាប់ទាំងព្រះឥន្ទ្រា ចាប់ទាំងព្រហ្មា ចាប់ទាំងទេវតាទាំងបរិវារក្ដា ផាហើយយកក្បាលកុម្ភណ្ឌទាំងប្អូន វាទៅចោមជុំហ៊ុំចាប់ឱ្យបាន កាលណោះឯកអង្គស្វាសហនុមាន និម្មិតប្រែប្រាណប៉ុនភ្នំបព្វតា ទៅចាប់កុម្ភណ្ឌបានបី វាយបំបែកសិរសា យក្សក្ស័យមរណា កាលពេលថ្ងៃនោះហោង រត់រួចយក្សមួយ ទៅទូលកុម្ភណ្ឌបុរណាភាត ថាអង្គម្ចាស់សិរសា ក្បិណនោះមានស្វាសកាចក្រៃ ធាត់ធំស្គឹមស្គៃ មនោមានះសោះសា ចាប់បានយក្សាទាំងបីអង្គា ចាប់បោកក្បិណក្ស័យប្រល័យជន្មា កុម្ភណ្ឌបុរណាភាត ក៏បានស្ដាប់ពាក្យកុម្ភណ្ឌដូច្នោះហើយ ក្រុងយក្សក៏ខឹងក្រេវក្រោធពិរោធសោះសា ស្រែកហៅ



— ... Il (INDOHJIT) transforme son corps, nait en braḥ INDR, emmène les filles du paradis offrir des dances. Devaputr, Devatā, jouent de la musique céleste, vraiment très belle, propre à émerveiller ... (§. 43)



— ... L'UN MUNG plane, se dirige au milieu de l'atmosphère ... (§. 43)



ពួកពលក្នុងព្រៃហោចវា ធ្លាយើងទាំងរស់ធ្លាមកជួយចោមចាប់ អាមនុស្សា ហានទាំងស្តេចស្វា ធាត់ធំស្លឹមស្លែ ពលយក្សាប្រាំម៉ឺនប្រាំពាន់សោតសល់ ចរចូលមកដល់ ដំបងពេជ្រគ្រប់ដៃ ស្តេចយក្សប្រាប់ថា យើងចូលទៅ វាយរាបនុស្សា ព្រះឥន្ទ្រាទេវតានៅក្រោមព្រះជ្រៃ ស្តេចយក្សបរពល ចូលដល់រណ្ដោលទីងដើមព្រះជ្រៃ យក្សហ៊ុំជុំជិត ខ្ទួលខ្មៅងងឹតបាក់ឈើ បាក់ព្រៃ ស្រីលក្សណ៍អនុជា ប្អូនភ្ញាក្សព្រថ្លៃ ដាស់ព្រះរៀមបង យក្សា មកច្រើនក្រៃ សុំព្រះរៀមជៀសជ័យ ស្តេចតើនឱ្យឆាប់ ស្វាស សហ-នុមាន ស្តេចតើនឱ្យឆាប់ យកព្រះខាន់ជ័យកាប់សម្លាប់យក្សា ព្រះនា-រាយណ៍រាបាស្តេចក៏តើនឡើង ស្តេចរាព្រះហស្ត ហៃបាហនុមានកុំទាន់ ធ្វើការ ចាំអញពិចរាកុំទាន់ធ្វើវា ព្រះអង្គដកដើមកក់កែវមកអធិស្ឋានថា ឱ្យកើតជាសរថ្លាព្រហ្មាសរឿងឫទ្ធី កក់កែវកើតជាសរសិល្ប ព្រះអង្គ ឃិតកៅទណ្ឌសរថ្លា ។ រាជក្របីស្រីពានរស្វាសសុទ្ធបុត្រព្រះពាយ សេនាអង្គព្រះនារាយណ៍បំផ្លាញអស់ពលយក្សា ស្លាប់យក្សប្រាំម៉ឺនប្រាំ ពាន់ត្រៀបត្រា ក្រុងអសុរាគ្មានសល់ដល់មួយ ស្តេចយក្សកុម្ភណ្ឌបូរណា-រាតយក្សា ក្រុងអសុរាស្រែកថ្ងូរខ្លាំងក្រៃ ដួលទៅកើតជាភ្នំធាធំស្លឹមស្លែ

កាលណោះសរព្រហ្មាសក្សត្រថ្លៃ ចាក់ឫសក្នុងដី ប្រាំរយយោជន៍យល់សរបែកជាមែកសំចេកខ្ពស់ក្រៃ បាំងសែងរស្មីសុរិយាព្រះអាទិត្យ សរវកដូងកែវយក្សពុំឃើញ បានជាយក្សនោះពុំស្លាប់ ស្រែកប្រាប់ហនុមានឱ្យយករអន្លូងវាយសរទៀតទៅ យក្សស្លាប់កើតជាភ្នំ ដកដង្ហើមធំក្នុងដីប្រេះផែនដី កើតជាស្ទឹង បើសត្វរមាំងរមាស ធ្លាក់ទៅកាលណោក្រុងអសុរាក៏បឺតយកទៅស៊ី សព្វថ្ងៃគេសន្មត់នាមថាភាពណ៍ធំ ។ ស្លេះត្រង់នេះសិនមិនចរចា និយាយពីព្រះនារាយណ៍រាមា ស្រីលក្សណ៍អនុជា សហ-នុមាន ព្រះអង្គពនេចរវិលថ្កាន ។ រឿងត្រង់ណោះស្លេះទុកនៅ ។

៧២-យើងនឹងថ្លែងទៅរាជសីតា ដែលនៅក្នុងនគរស្រីអយុធ្យា កាលណោះនាងអផ្សុកនៅពុំបាននាំរស់ស្រីស្នំបិរពារ បរចេញមកលេងទឹកស្រះស្រង់ អស់ពួកស្នំស្និទ្ធិស្រីង្គារហែរនាង សីតាមកច្រើនក្រៃ មកដល់ស្រះស្រង់វង្សបោក្ខរណី អស់ពួកស្រី១ហែលលេងសប្បាយ ខ្លះបេះបានផ្កាឈូករំចង់នូវស្បង់ជ ឈូកសែតឈូកស នូវឈូកច្រាលបេះបានបង្អួតបង្អរក្កា ខ្លះមុជពានពារក្នុងស្រះស្រី ថ្លែងពីរត្នរាជសីតាកែវកល្យាណ ស្រង់ទឹកកំសាន្តក្នុងព្រះទ័យ អស់ពួកសាវស្រីយកផ្កាំមកថ្វាយ លង់លុះសុរិយាបែរត្រជាក់ អស់ពួកនាងអ្នកឡើងប្រញាយ យើង



នឹងថ្លែងអំពីខ្មោចអាកុលកាឡកណ្ណីយក្ស វាកើតនឹងថ្មដាស្រះស្រង់វាស្គាល់រត្នរាជសីតាទៅស្រង់ទឹក វាខឹងណាស់ក្រេវក្រោធថា ព្រះនារាយណ៍រាមា សម្លាប់ពូជវាអស់ប្រាំពីរសន្តាន ក្នុងពេលនេះវាធ្វើឱ្យនាងសេតាព្រាត់ព្រះរាម កុំឱ្យជួបគ្នាវិញបាន ថាហើយប្រែប្រាណជាស្រីស្នំរបស់នាង លុះព្រះសុរិយាបែរទាបទៅ នាងនាំអស់សាវស្រីវិលវឹងថ្កាន ខ្មោចអាកុលកាឡកណ្ណីយក្ស ដើរតាមពីក្រោយ បានដល់រាជបូរីស្រីអយុធ្យា នាងសីតាឡើងទៅលើទែនក្រឡា ទូលនាងសីតាថា ម្ចាស់ក្សត្រីយ៍ដែលរាពណ៍លួចយកទៅបានដប់បួនឆ្នាំ ក្រុងរាពណ៍នោះដែលប៉ះក្សត្រីយ៍ឬទេ នាងសេតាប្រាប់ថា នាងស្រីស្នំកុំព្រួយបារម្ភនឹងអង្គអញ កាលក្រុងរាពណ៍លួចទៅបាន មិនដែលជិតប្រាណអង្គអញទេ បើមកជិតហើយក្ដៅដូចភ្លើងឆេះ ខ្មោចអាកុលកាឡកណ្ណីយក្សបានស្ដាប់ហើយ ទូលថាម្ចាស់អើយខ្ញុំមិនដែលឃើញទេ រូបរាពណ៍ទេតើ មុខមាត់វាយ៉ាងដូចម្ដេច នាងប្រាប់ថា ស្នំអើយវាអាក្រក់ណាស់ រូបវាគ្មានល្អដូចអស់គេ សម្បើមអាក្រក់គួរឱ្យខ្លាច មុខវាដប់ដៃវាម្ភៃ ចង្កូមសស្វាចគួរសម្បើម ខ្មោចអាកុលកាឡកណ្ណីយក្សទូលថា អង្គម្ចាស់ប្រាប់ខ្ញុំ ខ្ញុំមិនឃើញទេ សុំឱ្យម្ចាស់គូរឱ្យខ្ញុំឃើញ ទើបនាងយកក្ដារឈ្នួនព្រះរាមា មកគូរឱ្យសុទ្ធក្រុង

ភាពហោសូរ មុខដប់ដៃម្ភៃ មានគុជដីរដុះកណ្ដាលដើមទ្រូង ម្ល៉ោះហើយខ្មោចអាកុលកាឡាកណ្ដើយក្បលោតចូលក្នុងតំនូរ ឃើញខ្លួនមួយកំពោតបាត់សិរសា ព្រឺក្បាលព្រប់ភ្លា ថាខ្មោចលេង យូរបន្តិចក៏បាត់ទៅ នាងសីតាលុបហើយវាក៏កើតឡើងវិញ លុះថ្ងៃទន់ទាបព្រះរស្មី ព្រះនារាយណ៍នរបតីស្ដេចយាងដល់ នាងយកក្ដារឈ្នួនលាក់ក្រោមគ្រែ ដែលព្រះរាមាស្ដេចផែងផ្ទំ ស្ដេចយាងមកដល់ហើយស្ដេចថ្វាយបង្គំ ស្នំស្និទ្ធជិតជុំអង្គព្រះក្សត្រា ស្នំខ្លះកាន់ពាល់ ស្នំខ្លះលើកក្រយាស្ងោយថ្វាយក្សត្រា ស្ដេចសោយរួចហើយណោព្រះអង្គផ្ទំ អស់ស្នំមេធំក៏មូលមេផ្ទំគ្រប់ព្រះពោរ ព្រះនារាយណ៍រាមាពេលនោះផ្ទំពុំបាន ព្រាយវាលោលោបអង្គព្រះក្សត្រា វាឱបពីលើវាចាក់ពីក្រោមព្រះអង្គភ័យភិតតក្កមា ជូនកាលទទូរ ទៅឱបអង្គក្សត្រា ពេលនោះព្រះអង្គផ្ទំពុំបាន ព្រះអង្គស្រែកហៅព្រះលក្សណ៍ប្អូនភ្លា ប្អូនអើយពេលនេះបងនិទ្រាពុំបានយល់ដូចខ្មោចព្រាយទទូរសំពត់មកហើយឱនឱបក្រសោបបង លុះលង់ព្រឹកព្រាងមកកាលណា នាំព្រះប្អូនភ្លា មករើក្រឡាព្រះបន្ទំ រើទៅឃើញរូបរាពណ៍នៅនឹងក្ដារ ក្រេវក្រោធពោលសាទប់ពុំបាន ស្រែកហៅថា យើស្នំរាល់គ្នា មាននរណាចិត្តក្លាហាន មកគូររូបរាពណ៍ដាក់ក្នុងឋាន បើកាលណាដឹងឈ្មោះវាសម្លាប់



ឱ្យមរណោទុកពុំបាន ថាហើយអង្គក្សត្រក្សាន្តក្រេវក្រោធក្រៃ ព្រះនេត្រទុំទែងដូចអគ្គី កាលណោះរត្នរាជសីតាកែវកល្យាណ ចូលទៅឱបបាទាអង្គក្សត្រក្សាន្តថាខ្ញុំប្រាស់នេះឯងគូររូបរាពណ៍ ព្រះអង្គថាយើមីជូជាតិចោរអប្រិយវាស្រឡាញ់អារាពណ៍ប្ដីវាជូសាមន្យវាគូររូប ទុកមើលលេងកំសាន្តមីនេះទុកមិនបានក្នុងបុរី នៃមីសីតាអញលំបាកខ្លាំងណាស់ អញចង [illegible] ព្រាំពីរឆ្នាំ ស្ពាន់ដោយសារតែរូបនាងឯង អញទៅច្បាំងនឹងក្រុងយក្សាអស់ដប់បួនឆ្នាំ ដោយសារតែរូបនាង ឥឡូវនាងមិនគួរមកក្បត់អញ នាងយំហើយទូលថា សូមទ្រង់មេត្តាអត់ទោសទៅ ដ្បិតអីស្រីស្នំប្រើខ្ញុំគូរញ្ញិតនាងចង់មើល ព្រោះពុំដែលឃើញ ព្រះរាមឆ្លើយថា អើយមីសាមាន្យអញទុកមិនបានក្នុងបុរី ថាហើយហៅទៅកាន់ស្រីលក្សណ៍អនុជា យកខ្សែមកចាប់ចងយកទៅព្រៃ សម្លាប់វាឱ្យក្ស័យជីពជន្មា ព្រះលក្សណ៍ឮបងប្រើដូច្នោះហើយមិនហ៊ានបង្អង់ឡើយឱ្យយូរយារ យកខ្សែមកចាប់ចងជាចំណងបីជាន់ជាក់ចងក ចងជើងចងចង្កេះ ហើយដឹកបណ្ដើរព្រះនាងទៅ នាងទួញភ្លាមយាងភ្លាមតាមកម្មកាយ ឆោមឆាយកន្សែងថ្លែងសោកា ថាឱកូនស្ងួនអ្នកមាសម្ដាយ កូនអើយអ្នកនៅក្នុងផ្ទៃព្រះមាតា មិនដឹងជាស្រីឬប្រុសទេ មាតាម្ដាយក្ស័យព្រះជន្មថ្ងៃនេះហើយ លុះដឹកទៅដល់ក្នុងព្រៃជ្រៅ

ប្រាប់ព្រះលក្ស្មណ៍ថា ប្អូនពៅ ប្អូនសម្លាប់បងទៅកុំនៅយូរ នាងនិយាយនឹងកូនក្នុងព្រះឧទរថា កូនអើយអ្នកកុំរន់ចិត្ត ម្តាយក្ស័យជីវិតថ្ងៃនេះហើយ ព្រះលក្ស្មណ៍ប្អូនអើយសម្លាប់បងទៅ ស្រីលក្ស្មណ៍អនុជាបានស្តាប់សុវណ្ណីនៃនាងថាដូច្នោះហើយ មើលមុខព្រះខ័នថ្លា មើលទៅនាងសិតាដូចវង់ខែ ព្រះលក្ស្មណ៍ឱបព្រះបាទាយំសន្ទប់បាត់ដង្ហើមស្ងួនក្នុងសមសាន ថ្លែងពីនាងសិតាកែវកល្យាណ ថាឱប្អូនអើយស្រឡាញ់បងអ្វីដល់ម្ល៉េះ ប្អូនបងសោយសោកបាត់ស្មារតី យើងដើរក្នុងព្រៃតែពីរនាក់ ប្អូនដាច់ដង្ហើមហើយឬនៅឡើយ ប្អូនមិនសារសងនឹងបងវ៉ា នាងសិតាពិតក្នុងយោបល់ ចាំមើលបើព្រះលក្ស្មណ៍ភ្ញាក់ព្រះកាយា អញថាចាំរន់កុំឱ្យឆ្ងល់ លុះលង់ព្រះលក្ស្មណ៍ បានដឹងខ្លួនកាលណា នាងសិតាក៏ថា ឃើស្រីលក្ស្មណ៍អនុជា អញដឹងចិត្តបាឯងហើយ បានជាមិនកាប់អញទេទុកធ្វើប្រពន្ធ ថ្លែងពីព្រះលក្ស្មណ៍បានស្តាប់ព្រះនាងមានព្រះបន្ទូលដូច្នោះណា ក្រេវក្រោធសោះសាមិនមានស្បើយ ហូតព្រះខ័នហើយកាប់ព្រះនាង ព្រះខ័នក្លាយទៅកើតជាកម្រងផ្កាបាន ៣ ហើយណោពាក់ឱ្យនាង ទតមើលព្រះខ័នរលាយបាត់ យូរបន្តិច ក្លាយជាព្រះខ័នវិញ ព្រះលក្ស្មណ៍ខឹងណាស់ទាញព្រះខ័នកាប់ពីរដង ព្រះខ័នកើតជាកម្រងផ្កាដូចពីមុន ព្រះលក្ស្មណ៍មើលទៅបាត់ព្រះខ័នថ្លា ឃើញផ្កាកម្រង



នៅនឹងសុរ៉ងនាង ព្រះលក្ស្មណ៍ក៏ប្រឹងស្ទួងគ្រប់ ៣ ដង ហើយនាងកានកុលព្យបែនពិតហើយ ខ្ញុំកាប់នេះឱ្យកើតជាផ្កាកម្រងដូចពីមុន អធិស្ឋានរួចហើយ ក៏ចាប់ព្រះខ័នថ្លាកាប់ទៀតណោ ក៏ដូចពីដើម ស្រីលក្ស្មណ៍អនុជាប្អូនភ្ញា ឃើញដូច្នោះហើយក៏ក្រាបបង្គំថា ព្រះបងពនេចរទៅទៀតចុះក្នុងសមសាន ឱ្យបានសេចក្តីសុខ កុំកើតទុក្ខ នាងសីតាក៏លាស្រីលក្ស្មណ៍អនុជាពនេចរក្នុងសមសាន នាងលួងលោមទារិកាក្នុងផ្ទៃមាតាណោកូនអើយ មិនដឹងជាស្រីឬប្រុស បើយើងកើតក្នុងនគរស្រីអយុធ្យាមានស្រីស្នំក្រមការរំពេរំពៃ បើកូនកើតក្នុងព្រៃ កុំសង្ឃឹមថានឹងបានរស់ ។ ថ្លែងពីព្រះលក្ស្មណ៍ ចេញចរយាត្រាវិលមកវិញមកដល់ដើមពោធិជ្រៃមែកសាខា មានអារុក្ខទេវតារក្សាដើមពោធិជ្រៃ មុខគួរអាសូរព្រះលក្ស្មណ៍ណាស់ ទៅដល់នគរបូរីហើយ គ្មានភស្តុតាងទៅជូនបង អារុក្ខទេវតាកាឡាខ្លួនជារូបទ្រាយស្លាប់នៅក្រោយម្លប់ព្រះជ្រៃ ព្រះលក្ស្មណ៍ទៅដល់ហើយ វះវៀលឆ្លៀលយកថ្លើម យកទៅជូនបងកុំសង្ការ ឱ្យស្តេចស្មានថា ថ្លើមព្រះនាង ទៅដល់ហើយថ្វាយបង្គំជូនថ្លើមទ្រាយ ព្រះនារាយណ៍ឃើញហើយត្រាស់ទៅថា អូនអើយនេះហើយថ្លើមមីសីតា ថ្លើមធំខ្មៅអ្វីម្ល៉េះ វាក្បត់ប្តីអូនអើយកុំស្តាយវា ណាអូនអើយ ថាតែប៉ុណ្ណោះហើយស្តេចគង់ជាសុខសាន្ត ។ រឿងត្រង់នេះស្លេះទុកនៅ ។

៧៣- យើងនឹងថ្លែងទៅសីតាកល្យាណេ នាងព្រាច់ដើរក្នុងព្រៃសមសាន ព្រះរង់ព្រះមោចតែម្នាក់ឯង ទ្រង់ព្រះកន្សែងសោយសោកា ទឹកព្រះនេត្រាហូរស្រោកស្រាំរងៀសរការក្នុងកាយា នឹងថ្លែងទៅពីអង្គព្រះឥន្ទ្រាផ្ទំលើក្រឡាទែនពុំបាន ក្តៅក្រហាយគ្មានស្រាកស្រាន្ត ទតមើលមកឋានព្រៃព្រឹក្សា ឃើញនាងសីតាយាងតែម្នាក់ឯង ព្រះឥន្ទ្រានិម្មិតជាស្តេចក្របីមួយឈ្មោះបបិសេ្សា ដើរព្រាច់ក្នុងព្រៃ តែឯកោ ទៅឃើញព្រះនាងយាងតែឯង ក្របីព្រះឥន្ទ្រនិយាយទៅកាន់នាង និយាយថា នាងអើយ មកពីណាតែឯងឯកាក្នុងសមសាន កុំយាងទៅណាដើរតាមយើង ព្រោះពាននិយាយគ្នាជាកំសាន្ត ក្របីនាំនាងក្សត្រីយ៍វត្តរាជកល្យាណេ ព្រះឥន្ទ្រប្រញាប់ផែនដី បាន ៣ ទិវា ក៏ដល់ឋានព្រះមុនីឥសី សន្មតហៅថា មហាមេឃរាជព្រហ្មឥសីនោះរឿងឫទ្ធិ ឥតនរណាស្មើបាន ទោះយក្សយង់ក្រុងអសុរា ទេវតាសព្វឋាន ខ្លាចអំណាចឥសីមហាមេឃរាជព្រហ្ម ដើរក្នុងរាត្រី ៣ ទិវា អរុណរាងរះ បៀតព្រឹកព្រាងព្រះឥន្ទ្រក្លែងភេទវាត់ចោលនាងទៅគង់សុខសាន្តដូចពីដើម ថ្លែងពីព្រះមុនី ចេញមកសោយព្រះស្ងន់ពេលព្រឹក លុះឃើញនាងហើយក៏សួរថា ឧបាសិកឬឧបាសិកាមករកអ្វី នាងថា ព្រះពរថ្វាបង្គំ ឥសីរាជឧត្តមព្រះមុនី ខ្ញុំនេះជាវត្តបរបោសព្រះ



រាម គេយកបកកាប់សម្លាប់ក្នុងព្រឹក្សា មិនឲ្យយជីវាបំបរបង់ចោល ឥសីស្តាប់ហើយ ទ្រង់ញាណដឹងទាំងអស់គ្មានសល់ចន្លោះនឹងនេត្រា ចៅតាកុំទៅណា នៅនឹងនេះហើយ នាងបានស្តាប់ព្រះមុនីឥសីថាដូច្នោះហើយ ត្រេកអរក្រៃ ស្រីថ្លៃតែងយកវត្តប្រណិប័តន៍ បើព្រឹកព្រាង ស្វាងព្រះសុរិយា នាងតែងទៅបោសអាស្រម បេះផលាប្រគេនឱ្យលោកតាឆាន់ លុះបង់គភ៌នាងគប្រប់គ្រប់ ១០ខែ នាងនឹងប្រសូតរាជកុមារ ពេលយប់នោះណាបូលព្រះជីតាថា ឈឺព្រះបុមរខ្ញុំណាស់ នាងនឹងប្រសូតកូន ឥសីមានពុទ្ធដីកាថា ចៅអើយទៅសាលាក្រៅ កុំប្រសូតក្នុងព្រះអាស្រម កាលណោះនាងសីតានាងចរយាត្រាទៅសាលាក្រៅ ឥសីមិនបានចំរើនមេត្តាភាវនាទេ ទៅរក្សាព្រះនាងខំដើរផ្ទៀល ពេលនោះក្តៅក្រហាយដល់អណើសព្រហ្ម ប្រើស្រីសូតិាទាំង ៧ មកឱ្យជួយនាងផង កាន់ទឹកសុរាម្រិត ព្រះឥន្ទ្រាស្រោចអង្គានៃព្រះនាង ស្រីសូតិាក៏លាចុះ បានដល់នាងហើយ ចូលព្យាបាល នាងខ្លះទ្រជើងទ្រដៃ ស្រីខ្លះទ្រឧទរនឹងប្រសូតរាជកុមារក៏បានរូច កើតព្រះរាជបុត្រាប្រាណប្រុសប្រាកដ សម្បុរដូចមាស កាលពេលនោះស្រីសូតិាទាំង ៧ ហោះទៅសូតិាវិញ លុះលង់ព្រឹកព្រាង ស្វាងព្រះសុរិយា ឥសីមានពុទ្ធដីកាសួរព្រះនាង នាងអើយអម្បាញ់យប់

វិញ តើនរណាមាត់ច្រើនកុះករត្រង់ព្រះនាង នាងទូលពុទ្ធដីកាថា ស្រីសូគិាចុះមកជួយខ្ញុំ ឥសីថា នាងអើយកូននាងប្រុសឬស្រី នាងទូលពុទ្ធដីកាព្រះមុនីឥសី ថាកូនខ្ញុំប្រុសទេលោកតា ឥសីថាហើយ ពកូនចូលព្រះអាស្រមនាងកុំទៅក្រៅព្រះសាលា ព្បិតវីក្នុងព្រៃមានខ្មោចកំណាចព្រាយវាឆាបឆក់យកកុមារ នាងពព្រះរាជបុត្រហើយលួងលោមថា កូនអើយបើកូនកើតក្នុងឧទរស្រីអយុធ្យានាងស្រីស្នំក្រាបការ ព្យេងពរំពៃ ឥឡូវបាបុត្រមកប្រសូតនៅក្នុងព្រៃ មានតែមាតា ពាឥសី ថាហើយនាងក៏បីបុត្រចូលអាស្រមចងអង្រឹងផ្ដេកផ្ដៃ យោលរំពៃ កាលមានថ្ងៃមួយក៏នាងចូលទៅស្រង់ទឹកស្រះផ្ដាំនឹងលោកតាឱ្យមើលព្រះរាជបុត្រា នាងទៅស្រង់ទឹកស្រះហើយមានពានរស្វា ស្វាអ៊ូវមានស្វាឪ ស្វាក្រេះស្របូវក្នុងព្រៃព្រឹក្សា វាបីកូនវាមកផ្ទុតទឹកផង សីតាទតយល់ឃើញដូច្នោះហើយថា បងពានរអើយហេតុអ្វីបីកូនមកផង ស្វាថា កូនខ្ញីទុកនៅឯណាបាន មានសត្វខ្លែងធំៗ នៅក្នុងព្រៃ សត្វតូចវាយោភ័ក្ស យក្ស ឥន្ទ្រីយ វាឃើញកូនខ្ញីបីទៅស៊ី នាងក៏បានស្ដាប់ពួកស្វាថាដូច្នោះហើយ ភិតភ័យណាស់រហោសរហៅងឡើងពីស្រះមកបីរាជបុត្រក្នុងព្រះអាស្រម កាលណោះព្រះឥសីចូលទៅចំរើនឈាន នាងបីព្រះរាជបុត្រមកផ្ទុតទឹក លុះព្រះមុនីឥសីចេញមកវិញ



មើលក្នុងអង្រឹងបាត់កូននាង ឥសីលាន់មាត់ថា ឱបង់គំនិតហើយមានសត្វអ្វីបកឆាបឆក់កូននាងទៅស៊ី បើរត្នរាជសីតាមកពីស្រង់ទឹកកាលណាសួររកកូន បើមិនឃើញកូនឡើយ សោយសោកាយំរង្វូររំក្នុងព្រៃព្រឹក្សា ថាហើយកោលក្លែលអង្រឹងកងរត្តិ ដុតភ្លើងយកព្រះម្សិត(ក្របូន)ជប់សូនធ្វើជារូបកុមារ បើកូននាងរូបរាងយ៉ាងណា សុំឱ្យសិល្បកកើតដូចកូននាង ម្ល៉ោះហើយឥសីបោះទៅក្នុងភ្លើង កើតជាកុមារល្អដូចមាស រស្មីល្អណាស់ភ្លឺព្រោងព្រាយកើតជាកុមារដូច្នោះហើយ ឥសីរត់ឆ្វេលភ្លើងអគ្គី ថ្លែងពីរត្នរាជសីតាកែវកល្យាណ នាងពរព្រះរាជបុត្រា កុមារតូចចរចូលព្រះអាស្រម ឥសីឃើញថា ឱ នាងពកូនទៅផង តាភិតភ័យណាស់ ក្រែងសត្វអ្វីយកកូននាងទៅស៊ី តាជប់តាសូនរូបកុមារកើតឡើងកាលណាឮពី-សី បើដូច្នោះតារំលាយទៅវិញ នាងសេតាភ័យណាស់បង្គំទូល ខ្ញុំសុំតាកុំរំលាយ ខ្ញុំសុំយកមកជាកូនបានជាពីរ នាងក៏យកមកបំបៅទាំងពីរពង្សឆោមឆើតទ្រង់ទ្រាយល្អប្រពៃ កូនឥសីនឹងកូននាង មើលរូបរមើលរាងកូនឥសីសុទ្ធដូចគ្នា មានថ្ងៃមួយតាឥសីព្រះមុនី ហៅកុមារទាំងពីរមកជិតក្រែឥសីមានពុទ្ធដីកាថាហៃចៅថ្ងៃនេះមានឫកពារពិលាដោតជ័យ ឥសីថ្វាយព្រះពរដាក់ព្រះនាមបងថ្វាយនាមឱ្យហៅថារាមព្រះលក្សណ៍ ព្រះអនុជប្អូន

ថ្វាយនោះឱ្យហៅជប់ព្រះលក្ស្មណ៍ ទៅនាំឱ្យជាក់មកទៅតា ។

៧៤–កុមារនោះនិយាយពីរមាសុីតាកែវកេសមោ ឯងកែវក្បា បុត្រទាំងពីរប្រាណ ចូនធីគោរពគម្រប់ ៧ ឆ្នាំ ឥសីបិតឫស្សី កោសធ្វើធ្នូ ដាក់ព្រួញឱ្យពីរប្រាក់ ចៅឯងយកធ្នូនេះទៅរៀនបាញ់ទងផ្កាសោត ឯ ជើងព្រះអាស្រម ទៅបាញ់ឱ្យត្រូវកុំឱ្យខុសរាល់គ្រប់គ្រប់ ៧ ថ្ងៃ កុមារ ទាំងពីរតាមស្តាប់ពាក្យបិតា ថ្វាយបង្គំក្រាបលាទៅបាញ់ផ្កាឈើនោះ ធំត្រសុំភាគា កុមារនេះថ្វាយកធ្នូជារំភោគ ហើយក៏បាញ់បណ្តាក់ផ្កា ផ្កា ឥសីថាចៅបាញ់ឱ្យត្រូវកុំឱ្យខុស ក្សិណនោះរាជកុមារបាញ់បណ្តាច់ ទងផ្កា ជា ៧ថ្ងៃមិនដែលមានខុសសុទ្ធតែត្រូវ ឥសីហៅកុមារទាំងពីរពង្ស សួរថា ជប់ព្រះលក្ស្មណ៍ រាបព្រះលក្ស្មណ៍ចៅជីតា ចៅទៅរៀនបាញ់ ទងផ្កាខុសឬត្រូវ កុមារពីរពង្ស ពិតលោកតា ក្រាបទូលលោកតាត្រូវ ទាំងអស់ រៀនបាញ់៧ថ្ងៃមិនដែលខុស សុទ្ធតែត្រូវទាំងអស់ដូចប្រាថ្នា ថាហើយឥសីឱ្យកុមារទាំងពីររៀនមន្តព្រះគាថា ឱ្យខំសូធ្យទន្ទេញ ៣ យប់ ៣ថ្ងៃ នេះហើយមន្តបាញ់សរជ័យ ចប់អស់ហើយណា ចៅជីតារៀនរៀន មន្តកាប់ព្រះខាន់ ៣ យប់ ៣ថ្ងៃ កុមារទាំងពីររៀនចប់អស់គ្មានសង្ស័យ ទើបព្រះឥសីបង្ហាប់មន្ត ចំណេងឱ្យរៀនទន្ទេញ ៧ យប់ ៧ថ្ងៃ កុមារទាំងពីរ



រៀនចប់ទាំងអស់គ្មានសល់អ្វីសោះមន្តឥសី ឥសីប្រាប់ទៅថាបានដូចចិន្តា ចិត្តបំណង ឥសីយកព្រះម្សិតគីក្រមួនបោះទៅក្នុងភ្នក់ភ្លើងកងអគ្គីឥសីពត់ ព្រះភ្នែនពែនព្រះបាទបន្ទសិល្បសោត ហោមព្រះពិធី សុំឱ្យកើតធ្នូសរជ័យ ក្នុងកងអគ្គី ពេលនោះក៏កើតជាសរសិល្បរឿងឫទ្ធិក្រៃកើតអង្គទេវបុត្រ ឈរកណ្តាលភ្លើងលើធ្នូសរជ័យ ឡើងហុចឥសីមានទាំងព្រួញឱ្យមកតា ឥសីឈោងបានឱ្យបករាបព្រះលក្ស្មណ៍ ចៅអើយបើមានចម្បាំងនឹងយក្សា នឹងស្តេចមហាចក្រ ឯណាក្តី ចៅបាញ់តែសរពីរបានហើយកុំបាញ់សរ៣ ឥសីផ្តាំថាបើបាញ់សរ៣ កាលណាកើតភ្លើងប្រល័យកល្ប ឆេះផែនដី ឆេះឋានសួគ៌ាល័យ ឆេះព្រៃហេមពាន្ត អន្តរធានសត្វគ្មានសល់ ឆេះទព្វ ហេមសមុទ្រ សរពនេះខ្លាំងណាស់ ចៅជីតាបំរមបានអ្នកណាមើលមុខ បាន ហើយជប់ព្រះខ័នផ្កា ព្រះខ័ននោះហៅមហារឿងឫទ្ធិក្រៃ យក្សយង់ក្រុងអសុរី កាប់ស្លាប់មិនមានសល់ ប្រាប់រួចស្រេច ព្រះ មុនីមហាឥសីយកធ្នូសរជ័យ ព្រះខ័នថ្វាឱ្យទៅរាមព្រះលក្ស្មណ៍កាន់កំដរ ដៃ ឥសីដុតភ្លើងកងអគ្គីម្តងទៀត ឥសីជប់ធ្នូសរព្រះខ័នជ័យរឿងឫទ្ធិ ខ្លាំងក្រៃកម្រោបផែនដីបាន ទោះក្រុងយក្សាម៉ឺនសែនសមុទ្រ យក្សគេច មិនផុតពីមុខសរចៅអញ សរជ័យសោតមានឫទ្ធី ហើយជប់ព្រះខ័នជ័យ

សរបងដាក់ឈ្មោះថាសរ សរវិជ័យ សរប្អូនថាឈ្មោះ ព្រហ្មាស សរផ្កាញញី ឥសីប្រាប់ថា ទៅរើរកសរពីតាព្រាញ់រស់ពីរការហើយ កុំបាញ់សរ ៣ មិនបានទេចៅតា ឥសីប្រាប់ថា ទៅរៀនក្បែនសរ (បាញ់សរ) ៧ថ្ងៃទៅរៀនកាប់ព្រះខ័ន ៧ថ្ងៃ កុមារពីរពង្សកាលណារៀនចេះចប់សព្វរស់ហើយ លាគ្រូអាចារ្យនិងមាតាដើរលេងព្រៃ ថ្ងៃរសៀលជ្រេងជ្រេទេរសុរិយា ស្តេចមើលមាតាឥសី ធ្នូសរខ័នជ័យកាន់គ្រប់ដៃបេះបានផ្លែល្មុតបង្សុកសេដា ហាក់ប្រេងហាក់ក្រាងធូរបែនសេរហាន់ បានផ្លែហ៊ាកបានលាំងសាត ចូវេនសេដាបង្សុកល្មុតខ្នុរហោំងយកបកថ្វាយមាតាគ្រូអាចារ្យព្រឹកឡើងឆាន់ នាងសីតាសួរថា បាទាំងពីរពង្សកូនកុំដើរទៅលេងឆ្ងាយក្រែងកោនយក្សយង់ក្រុងអសុរា គ្រុឌនាគបក្សាធាធំក្រៃ ព្រៃនេះកូនអើយហៅព្រៃហេមពាន្ត សុទ្ធតែតេរុកហោះធ្យាន ទើបមកដល់ខ្លាតូចខ្លាធំសត្វសិង្ហពោ សត្វគ្រុឌ វាយោភក្សយក្សឥន្ទ្រីយ សុទ្ធតែធាធំប៉ុនភ្នំបព្វតា អ្នកកុំទៅឆ្ងាយ កុមារទាំងពីរ លាព្រះមុនីនិងឥសីមុនីតែងពនេចរទៅលេងជារាល់ថ្ងៃ ១ថ្ងៃទៅលេងឆ្ងាយបន្តិច នាំបងប្អូនព្រាច់លុះលេចដល់ព្រៃឆ្ងាយ ទៅឃើញរាំងកល្ប ១ដើមធាធំក្រៃ ស្លឹកដល់អរជដាកាស បញ្ចូលបាំងសែងព្រះអាទិត្យរ័ព្ទរស្មី ឬសចាក់ក្នុងផែនដីប្រាំរយ



យោជន៍យល់ រាំងនោះទំហុំមួយសែនឱប កុមារទាំងពីរឆ្ងាយឆ្ងល់ណាស់ទាំងប្អូនទាំងបង មិនដឹងថាដើមអ្វី លុះព្រះសុរិយាជ្រេត្រជាក់ ព្រះអង្គបេះបានបួលផលាច្រើនពេកក្រៃ វិលមកអាស្រមព្រះមុនីឥសី ចូលទៅថ្វាយបង្គំមាតាលោកតាថ្លៃ ស្រេចហើយពិតពុទ្ធដីកា តាឥសី លោកតាដើមអ្វីធំលើសគេ ស្លឹកវាបាំងសែងព្រះអាទិត្យ ឥសីថា ចៅជីតា ទៅធ្វើអ្វីឆ្ងាយប្លែះ អាចឈ្មោះឈើនោះហៅរាំងកល្បឬសវាចាក់ប្រាំរយយោជន៍យល់ ទៅក្នុងដី ស្លឹកបាំងបារមីសែងព្រះអាទិត្យ ចៅអើយ ស្តេចរាំងកល្បនោះធំណាស់ ទំហុំ ១សែនឱប ចៅអើយកាលគេទើបកផែនដីឈើនោះនៅតូចណាស់ ប៉ុន្តែបែកជាច្រើនក្រៃ លុះដល់មកសព្វថ្ងៃធំលើសគេ កុមារនៅនឹងតាឥសី ៣ទិវា លុះវេលាព្រឹកព្រាងប្រគេនផលាលោកគ្រូអាចារ្យឆាន់ តាឥសីឆាន់រួចហើយ ស្តេច ៣ អង្គាទ្រង់សោយផលាភោគ្គាបរិបូណ៌ក្រៃ សោយរួចលាមាតា តាឥសី ស្ពាយធ្នូសរកាន់ខ័នជ័យ យាងកាត់តម្រង់ត្រង់ដើមឈើធំ ទាំងប្អូនទាំងបងប៉ងប្រាថ្នាដល់បកកាលហោពោលពិគ្រោះគ្នា អូនអើយសរសិល្បរបស់យើង ៗមិនដែលបានបាញ់សោះ ម្តងនេះ ពេលនេះយើងល្បងសរថ្លា សរយើងនេះមានឫទ្ធិចេស្តា តាប្រាប់មកយើងថា កុំបាញ់សរ ៣ ថាហើយរាមព្រះលក្សណ៍

ចាប់សេរថ្លៃ ចាញ់ដើបព្រីក្សា កាលនោះម៉ែ បាក់មែករាំងពីរ ទៅធំក្រៃ កក្រើកផែនដី ពុំអាចតៀប រាប់ព្រះលក្ខណ៍ទៅសារកញ្ចៀបៀត ពុំអាចតៀប -ចារប្រួមផែនដី ក្រាំរយយោជន៍ការល់ ដាក់ប្រុសពេភីររត់រិន សល់ឡើយ រាំងកល្បនៅមិនបានរលំ ខ្លាំងក្រៃកក្រើកផែនដី ៧ សត្តទិវា កក្រើកព្រះអាស្រមដូចគេរំលើងរលំជើងភ្នំបញ្ចា កក្រើកឋានសូគិាល័យ គម្រប់ជា ៧ថ្ងៃ កក្រើកនគរស្រីអយុធ្យា ព្រះនារាយណ៍រាមានៅពុំបាន កក្រើកនគរកៃយកេតបូរី ភិរុតសមុទ្រទ្រុត លើកទ័ពភ័យសារ មានទ័ពពីណាមកវាយយកនគរបងអញ ព្រះរាមព្រះលក្សណ៍រស្មារ្យលើករសំពលហ្វា ថាមានទ័ពពីណាមកវាយយកនគរប្អូនអញ បងលើកទ័ពទៅប្អូនលើកទ័ពមកប្រជល់ទ័ពគ្នា នៅនាកណ្តាលផ្លូវ ព្រះរាមសួរទៅសមុទ្រទ្រុតប្អូនភ្ងា បងខំលើកទ័ពមក ក្រែងមានទ័ពពីណាមកវាយយកនគរប្អូន ភិរុតសមុទ្រទ្រុតទូលព្រះរាមបង ខ្ញុំគិតស្មានថាមានទ័ពពីណាមកវាយយកនគរបង ភិរុតសមុទ្រទ្រុតលើកទ័ពទៅវិញ ព្រះនារាយណ៍រាមាលើកទ័ពមកវិញ ។

៧៥-កក្រើកនេះសព្វឋានមិសមី ដូចកាលរង្គព្រះរិពោឱ្យរើងទាំងរសំញ្ញាថ្លែងសព្រាបញ្ញាជាប្តង ថាហើយឱ្យរាមាព្រទៅររញ្ជើញពិភេកសោបកគល់ធ្នូរ បេករាឱ្យជាក់ច្បាស់ រាមាព្រក៏ទៅររញ្ជើញពិភេកររសុភា ដល់



ហើយមកថ្វាយបង្គំព្រះអវតាន ព្រះនារាយណ៍រាមាត្រាស់ថា ហៃពិភេក ព្រះអនុជប្អូន កក្រើកទឹកកក្រើកដី សួរស័ព្ទអ្វីខ្លាំងក្រៃ ពិភេកក្រាបទូលថា ៖ គ្មានទ័ពនរណាដ៏ទៃ គឺទ័ពព្រះញាតិវង្សព្រះអង្គឯងនៃ កុមារនោះតូចក្រៃអាយុ ៧ ឆ្នាំ មិនមានច្រើនទេពីរនាក់បងប្អូន បើតាមលេខសាស្ត្រស័យពោលដោយហោរថា ៖ ព្រះអង្គត្រូវជាប្រដៅបាន កុមារតូចៗទាំងពីរអង្គព្រាហ្មណ៍រឿងឫទ្ធិបៅបាកឥតស្តេចឯណាបកផ្ចឹបផ្តល់បាន ព្រះនារាយណ៍រាមា សួរទៅពិភេកសោ បើពុំអាចយ៉ាងនេះយើងរកដូចម្តេចឃើញ ពិភេកទូលថា ៖ បើចង់ឃើញអ្នកបុណ្យពីរពង្សអង្គ ឱ្យយកសេះមកចងគ្រឿងរចនាយកកន្លសោ (ស្លុចសេះចេះហោះ) ចងគ្រឿងរចនា ល្អល្អះបញ្ចង់ ឱ្យកោរបណ្តាញកោសពាសលើខ្នងរាជានេយ្យ (មាសគ្រែប) ឱ្យយកសុពណ៌ផែនមាស (សុពណ៌ផែនមាស មាសគេយកមកចងក្បាលសេះ) ជូតក្បាលអាជានេយ្យ ដាំត្បូងដាំពេជ្រលាយលេចរស្មី សរសេរអក្សរ ថាបើនរណាហ៊ានច្បាំងនឹងព្រះរាមទើបហ៊ានជិះសេះនេះបាន រួចយកទៅប្រសង បើអ្នកបុណ្យពីរពង្សនៅត្រង់ណា ឱ្យយកសេះទៅត្រង់នោះ ព្រះនារាយណ៍សួរថា ៖ តើប្រើនរណាក្លាហសេះបាន ពិភេកឆ្លើយថា ប្រើហនុមាន ព្រះនារាយណ៍រាមាត្រាស់ប្រើហនុមាន សហនុមានក៏នាំព្រះអវតានលើ

ព្យួងសិរសា ត្រាស់ប្រើដូច្នោះហើយ ក៏យកគ្រឿងអលង្ការសង្វារពេជ្រមក ទ្រង់ម្កុដកែវរចនា យកព្រះខ័នថ្វាមកទ្រង់កាលណា ដើរតាមសេះទៅបើ សេះនោះហោះ ហនុមានហោះតាម បើសេះនោះស៊ីដើរនឹងដី ហនុមាន ក៏ឡើងដើមឈើទើតមើលនៃសេះមង្គល និយាយពីកុមារទាំងពីរពង្សដល់ ព្រះរាស្រមឡើងថ្វាយបង្គំព្រះជីតា ពាឥសីថាចៅអើយ ហេតុអ្វីបាន ទៅបាញ់រាំងកល្ប កុមារពិតពុទ្ធដីកាថា លោកតាខ្ញុំចង់ដឹងឫទ្ធិសរសិល្ប៍ ទៅថាអាស្រ័យព្រះតាតា ព្រោះថាគួរអើយ ហេតុអ្វីទៅបាញ់រាំងកល្ប កុមារ ទាំងពីរក្រាបទូលថា ចង់ដឹងឫទ្ធិសរសិល្ប៍បានជាធ្វើដូច្នោះ ការណ៍តាក្រៃ កល្បាណ កាលណាបានស្តាប់ កុមារទាំងពីរក្រាបទូលថាដូច្នោះហើយ មាតាព្រួយព្រះទ័យ ព្រោះព្រះចិន្តាព្រែងដឹងដល់ទៅព្រះបិតា កើតហេតុ ភេទក្នុងថាន កាលកុមារទាំងទៀតកុមារថ្វាយបង្គំលោកតា ព្រះតាតា ស្តេច ចេញព្រៃចេញចាកឋាន រាស្រមព្រះមុនីហើយ ដើរលេងក៏សោត្តស្តេច លេងទៅដល់វាលកាលមេវាល កាលនោះសេះមង្គល ដើរឆ្ពោះមកសេះ សេះ នោះព្រាត់ត្រង់តម្រង់មកដល់វាលកាលវាដូច្នោះហើយ រាមព្រះលក្សណ៍ ក៏បានឃើញសេះ និយាយទៅកាន់ព្រះអនុជ ជបព្រះលក្សណ៍ប្អូនអើយ សត្វនេះបងមិនដែលស្គាល់ឡើយ ប្អូនអើយគេហៅថាសត្វអ្វី ជប់



លក្សណ៍ទូលថាព្រះរៀមបង ខ្ញុំប្អូនមិនដែលស្គាល់សោះតែម្តង ទូល ព្រះរៀមបងសត្វនេះ ប្រហែលគេធ្លាប់ជិះ មើលទៅមានគ្រឿងប្រដាប់នៅ លើខ្នង ទាំងខ្លួនទាំងក្បាលទាំងអស់ សុទ្ធតែគ្រឿងរចនា បងមើលទៅ ហើយយល់ការ ថាប្អូនអើយ សត្វនេះគេធ្លាប់ជិះ ប្អូនអើយមកយើងចោល ចាប់វាឱ្យបាន ថាហើយក្សត្រក្សាន្ត ស្តេចពម្រង់ កាលណោះមនោម័យ ស្តេចរាជកន្លស ឃើញស្តេចកាត់ត្រង់តម្រង់ទៅ សេះក៏ឈប់នៅរង់ចាំ ក្សត្រារាមព្រះលក្សណ៍ ជបព្រះលក្សណ៍ ដល់ហើយក៏ចាប់សក់សេះ ឃើញសុពណ៌ផែនមាសល្អអស្ចារ្យ ឃើញអក្សរនៅនឹងផែនមាស អក្សរ ប្រាប់ថានេះសេះព្រះនារាយណ៍ បើនរណាហ៊ានចាប់សេះនេះជិះ អ្នកនោះ ហ៊ានច្បាំងនឹងអង្គព្រះនារាយណ៍ ប្រាប់ជបព្រះលក្សណ៍ថា : នេះហើយ សត្វសេះ ប្អូនឯងមើលចុះសារអក្សរ មិនមែនសេះឯណោ សេះព្រះនា-រាយណ៍ ប្អូនអើយព្រះនារាយណ៍ក៏ព្រះនារាយណ៍ចុះ យើងចង់ច្បាំងគ្នា នឹងព្រះនារាយណ៍ម្តង ប្អូនរត់មុខសេះមុនទៅបងជិះដេញ ជបព្រះលក្សណ៍ រត់មុនមុខសេះលឿនដូចខ្យល់ រាមព្រះលក្សណ៍ជិះដេញលឿនសោះសា មិនជិតមិនឆ្ងាយគ្រាន់តែល្អ ថ្លែងពីរាជក្របីស្រីពានរ សហនុមានឃើញ ហើយក៏ក្រោកអរ អញមិនបង្ហាញខ្លួនទេ ពួនក្នុងព្រៃ ចាំវាសោម៉ន

តាំងចាប់យក កាលណោះរាមព្រះលក្សណ៍ ជិះសេះដេញប្អូនមិនទាន់ឡើយ ដល់ឆ្លងវាលនោះទៅនៅខាងព្រៃ ជបព្រះលក្សណ៍ជិះសេះដេញបងម្តង បងឯងរត់ ប្អូនជិះម្តង រាមព្រះលក្សណ៍រត់លឿនដូចខ្យល់ ជបព្រះលក្សណ៍ជិះសេះដេញបងក៏ពុំទាន់ មិនឃ្លាតឆ្ងាយទេញូវពេញ រាមព្រះលក្សណ៍ថា : ប្អូនអើយជិះដូច្នេះមិនកើតទេ ហៃប្អូនកោសរុង ត្រូវជិះទាំងអស់គ្នា រាមព្រះលក្សណ៍ជិះមុខ ប្អូនជិះក្រោយ ស្តេចឱបបងហើយ សេះលឿនក្រៃ ទៅដល់ព្រៃព្រាងហើយបកបកវិញ ថ្លែងពីសហនុមានត្រេកអរ សល់បំពារប្រាប់ព្រៃឱ្យជិតរង្គចិត្តចង់ ស្ទុះទៅក្របោបឱបស្តេចទាំងពីរពង្ស ជិះទៅចំព្រង់ សហនុមាន ស្វាសក៏បានស្ទុះទៅក្របោបឱបពុំទាន់ ជបព្រះលក្សណ៍វាយខ្លាំងក្រៃ ត្រូវទីងចង្កួយធ្ងូ ជបព្រះលក្សណ៍កណ្តាលចិញ្ចើម ស្លាប់ស្តុកស្លាប់ស្តឹងវឹងទាំងខ្លួនជបព្រះលក្សណ៍ទូលថា បងអើយស្វាសនេះធំណាស់ ស្វានេះមានប្តាស់តែប្រើមកបានជាមានគ្រឿងរលង្ការក្រុងរាជ ណោ សង្ការទិព្វ នាំបងប្អូនឈរមើលទាំងពីរពង្ស សេះក៏ឈររង់ចាំរង្គក្បត្រា លុះព្រះពាយបោកឡើងហនុមានរស់ក្រេវក្រោធខ្លាំងណាស់ទឹងក្បត្រា ហនុមានហួតព្រះខ័នបឹងរង្គក្បត្រា រាមព្រះលក្សណ៍ក្បត្រា វាយស្វាដួលសន្លប់បាត់ស្មារតីក្ស័យជន្មា ព្រះពាយបក់បកកាល



ណោ ហនុមានក៏រស់ដឹងខ្លួនប្រាណនិម្មិតជារង្គព្រះព្រហ្មធំមុខ ៤ កើតដៃ ៨ កាន់រាវុធថ្លាចូលច្បាំងនឹងកុមារទាំងពីរពង្ស រាមព្រះលក្សណ៍ទាញសរថ្លាវាយចិញ្ចើមហនុមានក៏ស្លាប់ទៀតស្លាប់ស្តុកស្លាប់ស្តឹង និម្មិតជាស្វាធំប៉ុនភ្នំស្ពឹមស្លែ ព្រះពាយបក់បោកមក រស់ឡើងរត់ចូលព្រៃសូធ្យបន្ទូលព្រះគាថា ក្រឡាខ្លួនកើតជាកូនស្វាតូចកំព្រោយ ១ កាន់ផលឈើផ្លែឈើតូចតែពុំ យកកកេចថ្វាយកុមារទាំងពីរពង្ស ជបព្រះលក្សណ៍ស្រែកថាវាយទៀតទៅ កុំឱ្យរស់នៅ ឱ្យវាក្ស័យ គ្មានអាណាទេ នេះហើយអាស្វាដូចស្រែ វាចង់តដៃមកនឹងយើង ថាតែប៉ុណ្ណោះយកចុងសរវាយវាត់ទៅចំហនុមាន ហនុមានក៏ក្ស័យព្រះជន្មាគម្រប់ជាប្រាំពីរដងក្នុងមួយថ្ងៃ ក៏យកចុងសរចារចិញ្ចើមដាក់ចំណោមជើងពាក្យថា : អាឯងទៅក្រាប់ប្តូរសរាងមកច្បាំងនឹងអញ ពោធិវង្សរំពោះប៉ុនខ្សែពាន ចារដៃក្រពាត់ចុងទៅក្រោយ ហនុមានក៏សន្លប់មិនដឹងខ្លួនឡើយ លុះព្រះពាយបក់មក ហើយក៏រស់វិញ ទាញបណ្តាច់ចំណង ខាំផងទាញផងមិនដាច់សោះសា ទាញណាស់ វិតណាស់ ស្ទើរក្ស័យជីវា នឹកខ្មាសអាក្មេងតូចៗ កើតប្រាំពីរឆ្នាំ ឱអញនឹងហោះទៅនគរកៃយកេតបូរី ឬ អញនឹងហោះទៅនគរស្រីអយុធ្យាទៅក្រាបទូលអង្គព្រះនារាយណ៍រាមា ថាហើយសហនុមានហោះទៅសួគ៌ាទៅដល់ឋានព្រហ្ម ធំសោតសល់ទៅថ្វាយ

បង្គំព្រះព្រហ្មសុំឱ្យព្រះអង្គស្រាយចំណងនេះរុះរោយចេញ ព្រះព្រហ្មថាយើសហនុមានចំណងនេះស្រាយឯណាបាន ចំណងអង្គព្រះនារាយណ៍ បើស្រាយចំណងនេះក្នុងឋានព្រហ្ម នឹងឆេះឋានព្រហ្មដប់ពីរជាន់ ហនុមានហោះមកឋានព្រះឥន្ទ្រា មកថ្វាយបង្គំព្រះឥន្ទ្រាឱ្យព្រះឥន្ទ្រស្រាយចំណង ព្រះឥន្ទ្រាថាស្រាយឯណាបាន ចំណងនេះរបស់ព្រះនារាយណ៍រាមា បើស្រាយនឹងឋានព្រះឥន្ទ្រក៏ឆេះឋានព្រះឥន្ទ្រទាំងអស់ ប៉ោះហើយក៏ហោះទៅឋានវិស្សកម្មទេវបុត្រ សុំឱ្យវិស្សុកម្មទេវបុត្រស្រាយចំណង វិស្ស-កម្មថា ស្រាយឯណាបាន ចំណងអង្គព្រះនារាយណ៍ទំនាយទាយថា បើស្រាយឋានណាឆេះឋាននោះ ប៉ោះហើយវិស្សកម្មទេវបុត្រគ្រាន់តែលដៃ ចំណងវិញជាប្រាំពីរជាន់ អង្គទេវបុត្រថាសហនុមានឱ្យអង្គហោះទៅប្រាប់អង្គព្រះនារាយណ៍រាមា ហនុមានថា ឱ អញនឹងហោះលើអាកាសានឹងខ្ទាស់ស្រីក្នុងនគរស្រីអយុធ្យា ឬ អញនឹងជ្រែកផែនដីទៅផុះត្រង់អង្គព្រះនារាយណ៍រាមា កុំឱ្យអ្នកណាដឹងការដល់មួយសោះ ថាហើយទៅជ្រែកផែនដីទៅផុះចំអង្គព្រះនារាយណ៍រាមា ព្រះនារាយណ៍រាមាព្រះអង្គក៏បានស្តាប់ដូច្នេះហើយ ថាយើងរណោះអើយក៏យកចំណងមកចងសហនុមានអញ ពួកត្រៃត្រិង្សពួកទេវតាទាំងអស់ថា កើតអស្ចារ្យជាក់ចំណង



សហនុមានក៏ខ្ទាសអស់ពួកកងសេនានូវស្រីផង លើកមូវផែនដីបានលើកភ្នំបាន វល្លិចំណងប៉ុនខ្សែពានទាញពុំដាច់ អូតថាឯងមេទ័ពធំ កាន់សុទ្ធតែភ្នំចោលយក្សា យក្សស្លាប់គោកនព្វមហាសមុទ្រ អំបោះប៉ុនខ្សែពានទាញមិនដាច់ កាលណោះអង្គព្រះនារាយណ៍ថា យើ នរណារៀនគ្រូជាប្អូយនឹងអញ យកចំណងមកចងស្តេចស្វាស ចំណងនេះចងហើយស្រាយមិនបានទេ បើស្រាយឋានណាឆេះឋាននោះ ព្រះអង្គសូធ្យមន្តព្រះពាចារូពរប្លាប់បានហើយ ព្រះអង្គស្រាយ ស្រាយរួចរាជក្របីស្រីពានរស្វាសសុទ្ធ សេនាអង្គព្រះនារាយណ៍ក៏ក្រាបទូលថា សុំទានក្រាបទូលព្រាស់លើត្បូងសិរសា អ្នកបុណ្យនោះតូច ១ រូបដូចទេវតារឿងឫទ្ធិអស្ចារ្យខ្លាំងក្រៃ ទោះយក្ស ឬ មនុស្សក្នុងផែនដី យកមកផ្ទឹមផ្ទេរយល់ពុំបាន·ខ្ញុំក៏បានពពាំងច្បាំងប៉ុន្មានដងប៉ុន្មានគ្រា អ្នកបុណ្យវាយខ្ញុំមរណាស្លាប់រាប់រយដង គ្មាននរណាតពាំងទៅច្បាំងផងមិនបានទេ មានទាំងធ្នូសរព្រះខ័នជ័យ កូនក្មេងតូច ១ រាយុប្រាំពីរឆ្នាំ ។

៧៦–ព្រះនារាយណ៍រាមាក៏បានស្តាប់ដូច្នោះហើយ ពុំប្បូរឡើយព្រះអង្គកោនព្រះឱង្ការ ត្រើនិលផាត់ឱ្យទៅអញ្ជើញប្អូនអញដែលនៅនគរកៃយកេតបូរី ឱ្យលើកទ័ពធំកងយោធា ចូលមកស្រីអយុធ្យា និលផាត់បានស្តាប់ដូច្នោះហើយ ក៏វិលទៅនគរកៃយកេតបូរី ទៅអញ្ជើញភិរុត

សមុតទ្រុតឱ្យលើកទ័ពសារចូលមកក្នុងនគរស្រីអយុធ្យា ព្រះនារាយណ៍រាមាក៏ប្រើព្រះលក្ស្មណ៍អនុជាប្អូនរួនរើយកេណ្ឌកងទ័ពយោធាទៅចាប់រុកបុណ្យក្មេងតូច ១ ព្រះលក្ស្មណ៍ឮហើយកេណ្ឌកងពួកពលសកលយោធា កាលពេលនោះភិរុតសមុតទ្រុត ក៏លើកពលសកលយោធាឡើងទៅថ្វាយបង្គំព្រះនារាយណ៍រាមាព្រះរៀមបង ដល់ហើយប៉ប៉ាយឱនកាយថ្វាយបង្គំព្រះនារាយណ៍រាមាមានព្រះឱង្ការត្រាស់ប្រើប្អូនថា បែរភិរុតសមុតទ្រុតអនុជប្អូន អញប្រើប្អូនឯងទៅច្បាំងនឹងក្មេងតូច ១ អាយុប្រាំពីរឆ្នាំ ទ័ពនោះរឹងល្បីងខ្លាំងក្រៃគ្មានទ័ពណាដីទៃខ្លាំងស្មើបាន ភិរុតសមុតទ្រុតបានស្តាប់ហើយ ពុំប៉ានបង្អង់ឡើយបរទ័ពចរចាកឋាន ពោធិសត្វបីអង្គា ស្រីលក្ស្មណ៍អនុជា ភិរុតសមុតទ្រុត ស្តេចបរពលមកច្រើនក្រៃ កក្រើកកញ្រ្កើកក្រឹកផែនដី សូរស័ព្ទខ្លាំងក្រៃដូចព្យុះព្យោមា រាមព្រះលក្ស្មណ៍ឮហើយគិតថ្លាបងប្អូន រួនរើយសូរស័ព្ទអ្វីខ្លាំងក្រៃ ជបព្រះលក្ស្មណ៍ទូលថា នោះហើយស្តេចស្វា ទៅទូលម្ចាស់វា យើងកុំព្រួយព្រះទ័យ បងកុំភិតភ័យច្បាំងឱ្យរស់កល រាមព្រះលក្ស្មណ៍ឆ្លើយថារួនកុំសង្កាបកព្រង់អញបង យើងនឹងប្រឡងឱ្យដឹងសិល្បសរថ្លា ម្ល៉ោះហើយកុមារទាំងពីរពង្សមកឈរភាគ្រង់មុខទ័ពសារ ថ្លែងពីភិរុតសមុតទ្រុតនឹងស្រីលក្ស្មណ៍



អនុជា ស្តេចលើកទ័ពសារចរចូលមកដល់ កាលណោះទ័ពស្រូចពានរច្រើនសល់ កុមារឃើញស្វាសកង្គល់ ស្តេចមិនបានថ្លែងសរថ្លា គ្រាន់តែផ្ទាត់បន្ទោះសរថ្លា ពួកស្វាក៏រាវអាចម៍ប៉ះឈើព្រៃ ស្វាខ្លះដូចគេនឹងរែកធ្វើរមីទែ ស្វារត់ចូលព្រៃគ្មានទៅបួយឡើយ កាលណោះស្តេចបីអង្គាដល់មកជួបគ្នាហើយនៃ ថាអាក្មេងចង្រៃជៀសពីមុខសរអញ បើមិនជៀសទេអញនឹងបាញ់ កុមារឆ្លើយថា ស្តេចបីអង្គាជៀសពីមុខសរអញបើតែខំបកក្បៀណក្ស័យជីវិត ស្រីលក្ស្មណ៍អនុជា ភិរុតសមុតទ្រុតរឿងរិទ្ធិថ្លែងសរព្រមគ្នាឱ្យក្ស័យជន្មា កុមារទាំងពីរពង្ស សរនោះមិនហ៊ានចំព្រះអង្គសរកាត់ពម្រង់ទៅព្រៃហេមពាន្ត កុមារលើកដៃអធិស្ឋាន ជបព្រះលក្ស្មណ៍ចាប់សរព្រហ្មាសបាន បាញ់អង្គក្សត្រក្សាន្តឱ្យក្ស័យជន្មាចាប់សរភ្លែតបាញ់ភ្លាបត្រូវដើមទ្រូងភិរុតត្រាំ ដួលកណ្តាលភឺនផែនដែនពសុធា ស្រីលក្ស្មណ៍អនុជា នាំសមុតទ្រុតដកទ័ពរត់ចេញ ហនុមានឃើញអង្គក្សត្រក្សាន្ត ស្តេចដួលកណ្តាលពសុធា ស្ទុះទៅក្បៀកឱបក្រសោបរាជា ខ្វាក់ក្បៀសពីមាត់វាដុះលាបសរព្រហ្មាសផ្លាញផ្លាក៏ដាច់ឬសព្រានពស់ស្ពក អស់ស្តេចបីអង្គា បាញ់រាជកុមារលើកទ័ពថយក្រោយអរទ័ពមកដល់ស្រីអយុធ្យា ឡើងទៅក្រាបទូលអង្គព្រះនារាយណ៍រាមា